ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

***

ឆ្នាំទី ៤ លេខ ១៩ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៩៦

# រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

# មាតិកា

## I ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១៧.០៥.៩៦ | ព្រះរាជក្រឹត្យ ជស/រកត/០៥៩៦/០១៦ តែងតាំងឯកឧត្តម អ៊ុង ផន ទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច ជាឧត្តមសេនីយ៍កិត្តិយស «ផ្កាយមាសបី» | ៧៧៩ |
| ១៨.០៥.៩៦ | ព្រះរាជក្រឹត្យ ជស/រកត/០៥៩៦/០១៨ តែងតាំងឯកឧត្តម នៅ ឡុង ជាអនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន | ៧៨០ |
| ០៨.០៥.៩៦ | ព្រះរាជក្រឹត្យ ជស/រកត/០៥៩៦/០២១តែងតាំងឯកឧត្តម ខៀវ មុត ជាអគ្គនាយក នៃអគ្គនាយកដ្ឋានក្រសួងបរិស្ថាន | ៧៨១ |


## II ទីស្តីការគណៈរដ្ឋមន្ត្រី

### ១—អនុក្រឹត្យ


| | | |
|---|---|---|
| ២៣.០៥.៩៦ | អនុក្រឹត្យលេខ ២៣ អនក្រ.បក ស្តីពីការកំណត់ពីទំនាក់ទំនងរវាងរាជរដ្ឋាភិបាល និង អគ្គិសនីកម្ពុជា | ៧៨២ |
| ១៦.០៥.៩៦ | អនុក្រឹត្យលេខ ៨២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៧៩៥ |
| ២១.០៥.៩៦ | អនុក្រឹត្យលេខ ៨៣ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ | ៧៩៦ |
| ២១.០៥.៩៦ | អនុក្រឹត្យលេខ ៨៤ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិ ជាកិច្ចបច្ឆាមរណៈ | ៧៩៧ |
| ២១.០៥.៩៦ | អនុក្រឹត្យលេខ ៨៥ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិ ជាកិច្ចបច្ឆាមរណៈ | ៧៩៨ |
| ២១.០៥.៩៦ | អនុក្រឹត្យលេខ ៨៦ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយទាហាន | ៧៩៩ |

២១.០៥.៩៦ អនុក្រឹត្យលេខ ៨៧ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិ នាយទាហាន ៨០០
២១.០៥.៩៦ អនុក្រឹត្យលេខ ៨៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨០២
២១.០៥.៩៦ អនុក្រឹត្យលេខ ៨៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨០៤
២១.០៥.៩៦ អនុក្រឹត្យលេខ ៩០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨០៥
២១.០៥.៩៦ អនុក្រឹត្យលេខ ៩១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨០៦
២៣.០៦.៩៦ អនុក្រឹត្យលេខ ៩២ អនក្រ.តត ស្តីពីការតែងតាំងទីប្រឹក្សារបស់ឯកឧត្តម ហុង ស៊ុនហួត ក្នុងឋានៈជារដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ៨០៧

## ២—សេចក្តីសម្រេច

២១.០៥.៩៦ សេចក្តីសំរេចលេខ ១៦ សសរ ស្តីពីការបង្កើតគណៈកម្មការសំរាប់រុករក និង ជួយសង្គ្រោះយន្តហោះ និង នាវាពេលមានឧប្បត្តិហេតុ ៨០៩

២២.០៦.៩៦ សេចក្តីសំរេចលេខ ១៧ សសរ ស្តីពីគណៈកម្មការរៀបចំអនុម័តរាល់វិធានការការពារបេតិកភណ្ឌស្ថាបត្យកម្ម និង នគរោបនីយកម្មនៃទីក្រុងភ្នំពេញ ៨១១

# III ការងារបណ្តាក្រសួង

## ១—ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

### ប្រកាស

២១.០៥.៩៦ ប្រកាសលេខ ៣៤៩ ផក.ប្រក. អនុញ្ញាតអោយក្រុមហ៊ុនយូតាយឡុង តូបាកូប្រូដាក់ ( YUE TAILONG TOBACCO PRODUCT Co.LTD ) បង្កើតរោងចក្របារីនាំចេញ ៨១៤
២៣.០៥.៩៦ ប្រកាសលេខ ៣៥០ បល.ប្រក ស្តីពីការបង្កើតការិយាល័យកិច្ចការអាស៊ាន ៨១៦

## ២—ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខា ប្រមាញ់ និង នេសាទ

### ប្រកាស


| | | |
|---|---|---|
| ១៦.០៥.៩៦ | ប្រកាសលេខ ២៨៨ ប្រក.កសក អនុញ្ញាតអោយបង្កើតរោងចក្រកែច្នៃផលផលផលរបស់ក្រុមហ៊ុន CAMBODIA THAI PROD PRODUCTS Co.LTD | ៨១៧ |
| ២២.០៦.៩៦ | ប្រកាសលេខ ៣១៣ ប្រក.កសក.ចត ស្តីពីការបង្កើតសួនសត្វ | ៨១៩ |


## ៣—ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

### ប្រកាស


| | | |
|---|---|---|
| ១៦.០៥.៩៦ | ប្រកាសលេខ ១២០/៩៦ ពម.មព.ប្រក អនុញ្ញាតអោយកាសែតឈ្មោះ «គំនិតកូនខ្មែរ» បោះពុម្ពចែកផ្សាយ | ៨២១ |
| ១៧.០៥.៩៦ | ប្រកាសលេខ ១២១/៩៦ ពម.មព.ប្រក អនុញ្ញាតអោយផ្ទេរសិទ្ធិចាងហ្វាងការផ្សាយកាសែត «សម្លេងនិស្សិត» | ៨២២ |
| ១៧.០៥.៩៦ | ប្រកាសលេខ ១២៨ ពម.មព.ប្រក អនុញ្ញាតអោយទស្សនាវដ្តីឈ្មោះ «ខាំបុឌាដាយរិចតូរី» CAMBODIA DIRECTORY បោះពុម្ពចែកផ្សាយ | ៨២៤ |
| ១៧.០៥.៩៦ | ប្រកាសលេខ ១២៩/៩៦ ពម.បល.ប្រក តែងតាំងលោកស្រី ប៉ាក់ មុនី ជានាយកខុទ្ទកាល័យក្រសួងពត៌មាន | ៨២៥ |
| ២៣.០៥.៩៦ | ប្រកាសលេខ ១៣៧/៩៦ ពម.មព.ប្រក អនុញ្ញាតជូនលោក ថេង ប៊ុនម៉ា បើកអាជីវកម្មរោងពុម្ពឈ្មោះ «ធី.ប៊ី.អរ» | ៨២៦ |


## ៤—ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

### ប្រកាស


| | | |
|---|---|---|
| ១៧.០៥.៩៦ | ប្រកាសលេខ ២០១ ប្រក.សក ស្តីពីការបង្កើតគណៈកម្មការដឹកនាំបច្ចេកទេសក្នុងគំរោងអភិវឌ្ឍន៍ផ្លូវជាតិ ១ តំបន់មេគង្គ ភ្នំពេញ–ហូជីមិញ | ៨២៧ |

## ៥—ទីស្ដីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

### ប្រកាស


| | | |
|---|---|---|
| ២២.០៥.៩៦ | ប្រកាសលេខ ៣៩៧ អយក.ប្រក ស្ដីពីការប្ដូរឈ្មោះអនុវិទ្យាល័យ ចក.ដីរល ទៅជា «អនុវិទ្យាល័យ ហេង សំរិន» ស្ថិតនៅក្នុងស្រុកអូររាំងឪ ខេត្តកំពង់ចាម | ៨២៩ |
| ២២.០៥.៩៦ | ប្រកាសលេខ ៣៩៨ អយក.ប្រក ស្ដីពីការប្ដូរឈ្មោះ វិទ្យាល័យខ្សាច់កណ្ដាល ទៅជា «វិទ្យាល័យ ហ៊ុន សែន ខ្សាច់កណ្ដាល» ស្ថិតនៅក្នុងស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល | ៨៣០ |
| ២២.០៥.៩៦ | ប្រកាសលេខ ៣៩៩ អយក.ប្រក ស្ដីពីការពង្រីកអនុវិទ្យាល័យទ្រៀល ទៅជា «វិទ្យាល័យ ទ្រៀល» ក្នុងស្រុកបារាយណ៍ ខេត្តកំពង់ធំ | ៨៣២ |
| ២២.០៥.៩៦ | ប្រកាសលេខ ៤០០ អយក.ប្រក ស្ដីពីការប្ដូរឈ្មោះអនុវិទ្យាល័យកោះចូរ៉ាម ទៅជា «អនុវិទ្យាល័យ ប៊ុន រ៉ានីហ៊ុន សែន កោះចូរ៉ាម» ស្ថិតនៅក្នុងស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល | ៨៣៣ |


## ៦—ទីស្ដីការក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

### ប្រកាស


| | | |
|---|---|---|
| ២១.០៥.៩៦ | ប្រកាសលេខ ៤៦៤ សកអ ស្ដីពីការតែងតាំងទីប្រឹក្សាក្នុងការបញ្ជូនពលករខ្មែរ ទៅធ្វើការនៅកោះតៃវ៉ាន់ | ៨៣៤ |

# I ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ ជស/រកត/០៥៩៦/០១៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស

អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃ រាជរដ្ឋាភិ - បាលកម្ពុជា ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **អ៊ុង ផន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច ជាឧត្តមសេនីយ៍ កិត្តិយស « ផ្កាយមាសបី » នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុក អនុវត្តអោយបានសំរេចព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៦*

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

* * *

**ព្រះរាជក្រឹត្យជស/រកត/០៥៩៦/០១៨**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស**

**អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ១៩៩៦

## ព្រះរាជបញ្ញត្តិ (ត) — ប្រការសម្រេច

**មាត្រា ១** : តែងតាំងឯកឧត្តម **នៅ ឈួន** ជាអនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ។

**មាត្រា ២** : នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះអោយបានសំរេច ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់តាំងពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

* * *

## ព្រះរាជក្រឹត្យជស/រកត/០៥៩៦/២១

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស**

**អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

* * *

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់ឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី

២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ១៩៩៦

**ត្រាស់បង្គាប់**

**មាត្រា ១** : តែងតាំងឯកឧត្តម **ខៀវ មុត** ជាអគ្គនាយកនៃអគ្គនាយកដ្ឋានក្រសួងគ្រប់គ្រងបរិស្ថាន ។

**មាត្រា ២** : នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា រដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិដ្ឋាន ទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

**មាត្រា ៣** ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា

**ជា ស៊ីម**

* * *

## II និតិវិធានគណៈរដ្ឋមន្ត្រី

### ១- អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ ២៣ អនក្រ.បក**

**ស្ដីពីការកំណត់ពីទំនាក់ទំនង**

**រវាងរាជរដ្ឋាភិបាល និង រដ្ឋសភាកម្ពុជា**

* * *

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី២

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

– បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៦/១០ របស់ព្រះករុណាព្រះបាទ **សម្តេចព្រះនរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត អគ្គិសនីកម្ពុជា ដែលជាក្រុមហ៊ុនទទួលខុសត្រូវមានកំណត់មួយរបស់រដ្ឋ

– តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

– គណៈរដ្ឋមន្ត្រីយល់ព្រមផង

## សំរេច

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១** : អគ្គិសនីកម្ពុជាសរសេរអក្សរកាត់ អ.ក ដែលបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៦/១០ ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៩៦ ត្រូវដំណើរការក្រោយពីការអនុម័តលើលក្ខន្តិកៈ និង ការចុះបញ្ជីធនធានដូចដែលកំណត់ដោយអនុក្រឹត្យនេះ ។ លក្ខន្តិកៈគឺជាចំណងផ្លូវច្បាប់រវាងរាជរដ្ឋាភិបាល ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និងក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គិសនីកម្ពុជា ក្រុមប្រឹក្សាភិបាល ប្រធានអគ្គនាយក និងមន្ត្រី បុគ្គលិក និយោជិតដទៃទៀត នៃអគ្គិសនីកម្ពុជា ។

**មាត្រា ២** : រដ្ឋជាម្ចាស់កម្មសិទ្ធិដំបូងនៃអគ្គិសនីកម្ពុជា ។ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និ ថាមពល និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុហៅថា (មន្ត្រីគ្រប់គ្រ ហ៊ុនរដ្ឋ) ជាតំណាងរួមរបស់រដ្ឋក្នុងការគ្រប់គ្រងអគ្គិសនីកម្ពុជាផ្នែកអាជីវក និងការស្វែងរកកំរៃ ។ ក្នុងន័យនេះមន្ត្រី គ្រប់គ្រងហ៊ុនរដ្ឋជាម្ចាស់ភាគហ៊ុនទាំងអស ដែលចេញដោយអគ្គិសនីកម្ពុជា ។

**មាត្រា ៣** : អនុក្រឹត្យនេះ នឹងត្រូវអនុវត្តចំពោះ អគ្គិសនីកម្ពុជានិងអង្គភាពចំណុះរបស់ខ្លួ ទាំងអស់ រហូតដល់ពេលដែលរដ្ឋលែងជាម្ចាស់ហ៊ុនភាគច្រើនក្នុងអគ្គិសនីកម្ពុជា អង្គភាពចំណុះ របស់ខ្លួន ។

**មាត្រា ៤** : រដ្ឋអាចលក់ភាគហ៊ុនរបស់ខ្លួនក្នុង អគ្គិសនីកម្ពុជាឬក្នុងអង្គភាពចំណុះណាមួយស្រប តាមនយោបាយនៃរាជរដ្ឋាភិបាល ។

**មាត្រា ៥** : ដោយអគ្គិសនីកម្ពុជាមានលក្ខណៈជាក្រុមហ៊ុនទទួលខុសត្រូវមានកំណត់ អគ្គិសនីកម្ពុជាទទួលខុសត្រូវចំពោះបំណុលរបស់ខ្លួនត្រឹមកំរិតតំលៃនៃធនធានរបស់ខ្លួនតែប៉ុណ្ណោះ ។ ការទទួលខុសត្រូវរបស់រដ្ឋក្នុងឋានៈជាម្ចាស់ហ៊ុននិងម្ចាស់កម្មសិទ្ធិក្នុងអគ្គិសនីកម្ពុជាឬ ម្ចាស់ហ៊ុនណាមួយទៀត អនាគតក្នុងអគ្គិសនីកម្ពុជាមានកំរិតត្រឹមតែដើមទុនដែលខ្លួនបានយកមកចូលប៉ុណ្ណោះ ។

**មាត្រា ៦** : អនុលោមតាមបទបញ្ញត្តិនៃអនុក្រឹត្យនេះ ព្រមទាំងច្បាប់ដទៃទៀតជាធរមាន អគ្គិសនីកម្ពុជានឹងប្រកបអាជីវកម្មដោយឯករាជភាព ហើយទទួលខុសត្រូវដោយផ្ទាល់ចំពោះកំរៃ និងការខាតបង់របស់ខ្លួន ។

**មាត្រា ៧** : ចាប់ពីពេលត្រូវបានបង្កើត អគ្គិសនីកម្ពុជាត្រូវទទួលជំណពីរដ្ឋក្នុងឋានៈជាម្ចាស់ និងជាអ្នកគ្រប់គ្រងលើវិនិយោគទុនលើវិស័យអគ្គិសនីទាំងអស់របស់រដ្ឋហើយមានភារកិច្ចគ្រប់គ្រង ដូចជា ដីធ្លី អាគារ សំភារៈបរិក្ខារដទៃទៀតដើម្បី ផលិត បញ្ជូន និង ចែកចាយថាមពលអគ្គិសនី ។

អគ្គិសនីកម្ពុជាត្រូវទទួលបន្ត នូវបំណុលព្រមទាំងកាតព្វកិច្ចដែលចុះក្នុងកិច្ចសន្យាដែលមានកន្លងមក ។ បុគ្គលិកជាមន្ត្រីក្តី ជានិយោជិតក្តីដែលរាជ រដ្ឋាភិបាលបានចាត់អោយបំរើការ មកទល់បច្ចុប្បន្ននេះនឹងក្លាយជាបុគ្គលិកផ្ទាល់របស់អគ្គិសនីកម្ពុជាតែម្តង ។ បុគ្គលិកទាំងនេះមិនមានសិទ្ធិទាមទារប្រាក់ឧបត្ថម្ភពិសេសអ្វីពីអគ្គិសនីកម្ពុជាដោយសារការផ្លាស់ប្តូរក្របខ័ណ្ឌវិជ្ជាជីវៈរបស់ខ្លួនឡើយ ។

## ជំពូកទី ២

## គោលដៅ សិទ្ធិ និងការទទួលខុសត្រូវរបស់ អគ្គិសនីកម្ពុជា

**មាត្រា ៨ :** អគ្គិសនីកម្ពុជា មានសិទ្ធិ និងមានការទទួលខុសត្រូវក្នុងការផលិត បញ្ជូននិងចែកចាយ ថាមពលអគ្គិសនីទូទាំងព្រះរាជាណាចក្រកម្ពុជា ស្របតាមការទទួលខុសត្រូវនិងកាតព្វកិច្ចនៃសេវាកម្មរបស់ខ្លួន ដែលកំណត់ដោយច្បាប់ លក្ខន្តិកៈ អាជ្ញាប័ណ្ណនិងបទបញ្ញត្តិផ្សេងៗ ទៀត នៃរាជរដ្ឋាភិបាល ។

**មាត្រា ៩ :** អគ្គិសនីកម្ពុជា ត្រូវដំណើរការជាសហគ្រាសអាជីវកម្ម មានឯករាជភាពក្នុងការផលិតបញ្ជូននិងចែកចាយនិងឆ្លើយតបអោយបានសមស្របតាមតម្រូវការទីផ្សារ ព្រមទាំង ទទួលខុសត្រូវលើសេវាកម្មរបស់ខ្លួននិងរកកំរៃបង្កើនធនធាន បង្កើតផលប្រយោជន៍សេដ្ឋកិច្ច និងបង្កើនផលិតភាព ពលកម្ម ។

**មាត្រា ១០ :** អគ្គិសនីកម្ពុជា ត្រូវគោរពលក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណដែលចេញ អោយដោយអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីបំរើសេវាកម្មអគ្គិសនីផ្សេងៗ ។ អគ្គិសនីកម្ពុជាត្រូវអនុវត្តអោយបានសំរេច ទិសដៅដែលបានកំណត់ក្នុងផែនការរបស់ក្រុមហ៊ុន និងរាល់លក្ខខ័ណ្ឌនៃគំរោងកិច្ចសន្យា ប្រតិបត្តិការរបស់ក្រុមហ៊ុនដូចមានចែងក្នុង មាត្រា ៤១ និង ៤២ នៃអនុក្រឹត្យនេះ ។

**មាត្រា ១១ :** អគ្គិសនីកម្ពុជាត្រូវកំរិតសកម្មភាពអាជីវកម្មរបស់ ខ្លួនត្រឹមតែអាជីវកម្មណាស្របទៅនឹងទំហំមុខរបរដែលមានចែងច្បាស់ក្នុងលក្ខន្តិកៈរបស់ខ្លួន និងអនុញ្ញាតដោយអាជ្ញាប័ណ្ណដែលអាជ្ញាធរអគ្គិសនីកម្ពុជាបានចេញអោយ ដើម្បីបំរើសេវាកម្មអគ្គិសនី ។

**មាត្រា ១២ :** អគ្គិសនីកម្ពុជា ត្រូវបានអនុញ្ញាតអោយទទួលរ៉ាប់រងការងារដូចខាងក្រោមនេះ ÷

១– ផលិត បញ្ជូននិងចែកចាយថាមពលអគ្គិសនី ក្នុងគោលបំណងបំពេញតម្រូវការរបស់អ្នកជាវគ្រប់ប្រភេទ ។

២– និហរណកម្មថាមពលអគ្គិសនីទៅប្រទេសជិតខាង និងអហរណកម្មថាមពលអគ្គិសនីពី ប្រទេសទាំងនោះមកវិញ ។

៣– ស្ថាបនានិងដំណើរការបណ្តាញអគ្គិសនីជាតិ សំរាប់បញ្ជូនថាមពល ដើម្បីធានាការផ្គត់ផ្គង់អោយមានប្រសិទ្ធភាព ។

៤–ស្ថាបនានិងដំណើរការបណ្តាញរណប សំរាប់ការចែកចាយថាមពលអគ្គិសនិ និង សំរបសំរួលការតភ្ជាប់ និងដំណើរការរបស់អគ្គិសនីកម្ពុជានិងបណ្តាញចែកចាយផ្សេងទៀត ។

៥–លក់ថាមពលអគ្គិសនី និងសេវាកម្មពាក់ព័ន្ធផ្សេងៗទៀត ។

៦–ទទួលទិញ ផ្ទេរនិងប្តូរថាមពលអគ្គិសនីពីផលិតករដទៃទៀត ។

**មាត្រា ១៣** : អគ្គិសនីកម្ពុជា មានសិទ្ធិចូលរួមក្នុងរាល់សកម្មភាពស្របច្បាប់ក្នុងវិស័យអគ្គិសនីសំរាប់បំពេញគោលដៅពាណិជ្ជកម្មរបស់ខ្លួន ។

**មាត្រា ១៤** : អគ្គិសនីកម្ពុជា អាចបង្កើតក្រុមហ៊ុនរណបដទៃទៀត មានលក្ខណៈជានីតិបុគ្គលដាច់ដោយឡែកពីគ្នា ហើយដែលទទួលខុសត្រូវផ្ទាល់រៀងៗខ្លួនស្របតាមច្បាប់ ។

**មាត្រា ១៥** : អគ្គិសនីកម្ពុជា ត្រូវការពារសិទ្ធិនិងផលប្រយោជន៍ស្របច្បាប់របស់បុគ្គលិកខ្លួន ហើយយកចិត្តទុកដាក់ក្នុងការបង្កើនផលិតភាព និងការពារសុវត្ថិភាពការងាររបស់បុគ្គលិកទាំងនោះ ។

## ជំពូកទី ៣

## ការចុះដើមទុន និង ធនធាន

**មាត្រា១៦** : ប្រភពដើមទុន អគ្គិសនីកម្ពុជាបានមកពី ÷

១–វិភាគទានគ្មានសំណង ដែលផ្តល់ដោយរាជរដ្ឋាភិបាល ។

២–ទ្រព្យសម្បត្តិផ្សេងៗ និង ដីធ្លីដែលរាជរដ្ឋាភិបាលបានផ្ទេរអោយអគ្គិសនីកម្ពុជាស្របតាមមាត្រា ៧ នៃអនុក្រឹត្យនេះ ។

៣–ប្រាក់ដែលចាត់ទុកជាដើមទុន ចេញមកពីការទូទាត់ជាក់ស្តែង និងស្របច្បាប់គណនេយ្យរបស់អគ្គិសនីកម្ពុជា ។

៤–ជំនួយឥតសំណងនិងជំនួយហិរញ្ញវត្ថុផ្សេងៗទៀតដែលអគ្គិសនីកម្ពុជាទទួលហើយមានការយល់ព្រមពីមន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋ ។

៥–ប្រភពទុនផ្សេងៗ ទៀតដែលអគ្គិសនីកម្ពុជា និងទទួលតាមការយល់ព្រមពីមន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋ ។

**មាត្រា១** : ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ត្រូវរៀបចំបញ្ជីការដែលមានកត់ត្រា អំពីធនធាន បំណុល និងកាតព្វកិច្ចចេញពីកិច្ចសន្យាទាំងឡាយ ដែលនឹងត្រូវផ្ទេរអោយ

អគ្គិសនីកម្ពុជា អនុលោមតាមមាត្រា ៧ នៃអនុក្រឹត្យនេះ តាមរយៈលិខិតផ្ទេរកម្មសិទ្ធិក្តី តាមកិច្ចសន្យាជួលក្តី តាមកិច្ចសន្យាប្រវាស់ក្តី រាប់បញ្ចូលទាំងសំភារៈបរិក្ខារ ដីធ្លី សំណង់ដែលរដ្ឋបានវិនិយោគមកហើយសំរាប់ ផលិត បញ្ជូន និងចែកចាយថាមពលអគ្គិសនី ។ ការចុះបញ្ជីនេះរាប់បញ្ចូលការប៉ាន់ស្មានតំលៃធនធានដូចដែលមានចែងក្នុងមាត្រា ១៨ នៃអនុក្រឹត្យនេះ ។

**មាត្រា១៨** : អគ្គិសនីកម្ពុជា ត្រូវរក្សាបញ្ជីការនេះ ដោយយកតួលេខតម្លៃធនធានផ្អែកទៅលើអត្រាថយតម្លៃរបស់វា ។

## ជំពូកទី ៤

## លក្ខន្តិកៈរបស់ក្រុមហ៊ុន និងការប្រព្រឹត្តិទៅ

**មាត្រា១៩** : ម្ចាស់ភាគហ៊ុនក្នុងអគ្គិសនីកម្ពុជាក្នុងឋានៈជាអ្នកផ្តល់វិភាគទានដល់ទុននៃអគ្គិសនីកម្ពុជាត្រូវ ប្រើប្រាស់សិទ្ធិជាម្ចាស់កម្មសិទ្ធិនៃអគ្គិសនីកម្ពុជាដូចដែលមានចែងក្នុងលក្ខន្តិកៈអគ្គិសនីកម្ពុជា ។ ក្នុងករណីដែលម្ចាស់ហ៊ុនមានចំនួនលើសពីមួយ ម្ចាស់ហ៊ុនម្នាក់ៗមានសំឡេងឆ្នោតក្នុងមហាសន្និបាតនៃក្រុមហ៊ុនតាមសមាមាត្រនៃភាគហ៊ុនរបស់ខ្លួន ។

**មាត្រា២០** : លក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវមានការយល់ព្រម ពីរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលហើយត្រូវចុះបញ្ជី និង ប្រថាប់ត្រាស្របច្បាប់ ។

លក្ខន្តិកៈនេះត្រូវបញ្ជាក់ចំណុច ពិសេសរបស់អគ្គិសនីកម្ពុជាដូចតទៅ ÷

១–អាសយដ្ឋាន ។

២–ទីកន្លែងនៃអាជីវកម្ម ។

៣–ទុនចុះបញ្ជី ។

៤–សិទ្ធិ និង ភាតព្វកិច្ចរបស់រដ្ឋក្នុងនាមជាម្ចាស់ហ៊ុន ។

៥–វិធីនិងចំនួនទឹកប្រាក់ដើមទុនដែលរដ្ឋដាក់បញ្ចូលជាហ៊ុន ។

៦–រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន មុខងារ សិទ្ធិអំណាយ និង វិធានការ ព្រមទាំង ទំរង់បែបបទ ការតេងតាំង ក្រុមប្រឹក្សាភិបាល និងមន្ត្រីក្រុមហ៊ុនដទៃទៀតនិង

៧–តំណាងអគ្គិសនីកម្ពុជាចំពោះមុខច្បាប់ ។

**មាត្រា២១** : ក្នុងករណីដែលរាជរដ្ឋាភិបាលមានបំណងលក់ភាគហ៊ុនរបស់ខ្លួនក្នុងអគ្គិសនីកម្ពុជា លក្ខន្តិកៈ នៃអគ្គិសនីកម្ពុជា ត្រូវកែប្រែដើម្បីបញ្ចូលចំណុចដូចតទៅ ÷

១–ឈ្មោះរបស់ម្ចាស់ភាគហ៊ុនទាំងឡាយ ។

២–សិទ្ធិ និង កាតព្វកិច្ចរបស់ម្ចាស់ភាគហ៊ុនទាំងនោះ ។

៣–ទម្រង់បែបបទសំរាប់ការចេញ និង ការពិនិត្យបញ្ជាក់ភាគហ៊ុន ។

៤–លក្ខខ័ណ្ឌសំរាប់ការប្រើប្រាស់ភាគហ៊ុនទាំងនោះដោយម្ចាស់ភាគហ៊ុន ។

៥–សិទ្ធិ មុខងារ ទម្រង់បែបបទនៃការពិភាក្សា និងការបោះឆ្នោតរបស់ម្ចាស់ភាគហ៊ុននៅក្នុងមហាសន្និបាតម្ចាស់ភាគហ៊ុន ដោយរួមបញ្ចូលកិច្ចការដែលទាមទារអោយមានការសំរេច ដោយសម្លេងឆ្នោតជាវិជ្ជមាន ៣/៤ ។

៦–ការចាត់តំណាងរបស់ម្ចាស់ភាគហ៊ុនក្នុងក្រុមប្រឹក្សាភិបាលតាមសមាមាត្រនៃហ៊ុន ព្រមទាំងនីតិវិធីសំរាប់ជ្រើសរើសក្រុមប្រឹក្សាភិបាល ។

**មាត្រា២២** : ក្នុងករណីដែលរដ្ឋជាម្ចាស់ហ៊ុនតែឯង អគ្គិសនីកម្ពុជាមិនត្រូវបើកអោយមានមហាសន្និបាតនៃម្ចាស់ហ៊ុនឡើយ ។ មន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋអាចអនុញ្ញាតអោយក្រុមប្រឹក្សាភិបាលរបស់ អគ្គិសនីកម្ពុជាទទួលខុសត្រូវ និងប្រើសិទ្ធិអំណាចនៃរាជរដ្ឋាភិបាលដែលជាម្ចាស់កម្មសិទ្ធិរបស់អគ្គិសនីកម្ពុជា ។

**មាត្រា២៣** : អគ្គិសនីកម្ពុជា ត្រូវមានក្រុមប្រឹក្សាភិបាលដែលមានចំនួនសមាជិកដូចដែលមានចែងក្នុងលក្ខន្តិកៈ ប៉ុន្តែមិនអាចលើសពី ៧ នាក់ឡើយ ។ ក្រុមប្រឹក្សាភិបាលត្រូវមានតំណាងរបស់ម្ចាស់ហ៊ុន និងបីនាក់ដែលត្រូវបានជ្រើសរើសក្នុងចំណោមសហគមន៍ពាណិជ្ជកម្ម ។ ក្នុងករណីដែលរដ្ឋជាម្ចាស់ហ៊ុនផ្តាច់មុខ មន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋជាអ្នកតែងតាំងនិងផ្លាស់ប្តូរសមាជិកទាំងអស់នៃក្រុមប្រឹក្សាភិបាល ។ អាណត្តិរបស់សមាជិកក្រុមប្រឹក្សាភិបាលត្រូវកំណត់នៅក្នុងលក្ខន្តិកៈ ប៉ុន្តែមិនអាចលើសពី ៥ ឆ្នាំឡើយ ។ អាណត្តិរបស់សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗអាចបន្តបានច្រើនដងជាប់ៗ គ្នា ។ សមាជិករបស់ក្រុមប្រឹក្សាភិបាលមិនអាចត្រូវដកពីមុខតំណែងបានមុនអាណត្តិដោយគ្មានមូលហេតុសមរម្យឡើយ ។

**មាត្រា២៤** : សមាជិកម្នាក់ៗនៃក្រុមប្រឹក្សាភិបាលត្រូវមាន កាតព្វកិច្ចផ្ទាល់ចំពោះអគ្គិសនីកម្ពុជា និងម្ចាស់ហ៊ុន ។ ករណីនេះទាមទារអោយសមាជិកទាំងនោះប្រកបភារកិច្ចនាទីរបស់ខ្លួនដោយស្មោះត្រង់ ហើយបំរើចំពោះតែផលប្រយោជន៍របស់អគ្គិសនីកម្ពុជា និង ម្ចាស់ហ៊ុន ។ សមាជិកក្រុមប្រឹក្សាភិបាល មិនត្រូវទទួលការប៉ះពាល់ជាបុគ្គលភាពឡើយ ចំពោះសកម្មភាពដែលខ្លួនបានបំពេញ ក្នុងឋានៈជាសមាជិកក្រុមប្រឹក្សាភិបាល

លើកលែងតែសកម្មភាពណាដែលផ្ទុយនឹងកាតព្វកិច្ចរបស់ខ្លួន ។

**មាត្រា២៥** : ក្រុមប្រឹក្សាភិបាលបំពេញកាតព្វកិច្ចរបស់ខ្លួនស្របតាមបញ្ញត្តិច្បាប់ ហើយលើស ពីនេះទៅ ទៀត ត្រូវទទួលខុសត្រូវ ÷

១–ពិនិត្យ អនុម័ត និងធ្វើអធិការកិច្ចលើការអនុវត្តន៍ផែនការក្រុមហ៊ុនដោយអនុលោមតាមមាត្រា ៤១ នៃអនុក្រឹត្យនេះ ។

២–ពិនិត្យ និង អនុម័តផែនការវិនិយោគ ។

៣–ពិនិត្យ និងអនុម័តបំណុលព្រមទាំងបែបបទហិរញ្ញវត្ថុផ្សេងៗទៀត ។

៤–ពិនិត្យ អនុម័ត និង ត្រួតពិនិត្យការអនុវត្តន៍កិច្ចសន្យាប្រតិបត្តិការអាជីវកម្មរបស់អគ្គិសនីកម្ពុជាដូចដែលមានចែងក្នុង មាត្រា ៤២ នៃអនុក្រឹត្យនេះ ។

៥–កិច្ចការផ្សេងៗ ទៀតដែលបានប្រគល់អោយក្រុមប្រឹក្សាភិបាលស្របតាមលក្ខន្តិកៈក្រុមហ៊ុន ។

**មាត្រា២៦** : ប្រាក់បំណាច់សំរាប់សមាជិកនៃក្រុមប្រឹក្សាភិបាល នឹងត្រូវកំណត់ដោយមន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋ ។

**មាត្រា២៧** : អគ្គិសនីកម្ពុជា ត្រូវមានប្រធានអគ្គនាយកមួយរូបដែលទទួលខុសត្រូវចំពោះកិច្ចការប្រចាំថ្ងៃរបស់អគ្គិសនីកម្ពុជាស្របតាមភារកិច្ចដែលបានចែងក្នុងលក្ខន្តិកៈ និងក្នុងបទបញ្ជាផ្ទៃក្នុងដែលក្រុមប្រឹក្សាភិបាលបានអនុម័ត ។ ប្រធានអគ្គនាយកអាចជាសមាជិកក្រុមប្រឹក្សាភិបាលផងដែរ តែមិនអាចជាប្រធាននៃក្រុមប្រឹក្សាភិបាលបានទេ ។

**មាត្រា២៨** : មន្ត្រីរាជការដែលកំពុងបំពេញការងាររបស់ខ្លួនជាប្រចាំ ពុំអាចត្រូវបានតែងតាំងបន្ថែមជាប្រធានអគ្គនាយក ឬ ជាបុគ្គលិកប្រភេទណាក្តី របស់អគ្គិសនីកម្ពុជាបានឡើយ ។

## ជំពូកទី ៥

## សិទ្ធិអំណាចខាងពាណិជ្ជកម្ម

**មាត្រា២៩** : អគ្គិសនីកម្ពុជា ត្រូវបានអនុញ្ញាតអោយធ្វើកម្មសិទ្ធិ កាន់កាប់ ប្រើប្រាស់ ជួញដូរ អចលនទ្រព្យ ចលនទ្រព្យទាំងឡាយស្របតាមច្បាប់ ។ ប៉ុន្តែការលក់ធនធានដែលមានតម្លៃស្មើ ឬលើសពី ៥០០.០០០ ដុល្លារអាមេរិកត្រូវមានការអនុម័តព្រមព្រៀងពីមន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋជាមុនសិន ។

**មាត្រា៣០** : អគ្គិសនីកម្ពុជា មានសិទ្ធិចុះកិច្ចសន្យា ឬកិច្ចព្រមព្រៀងអាជីវកម្មណាមួយក៏ដោយ ដើម្បីជួញដូរសំភារៈបរិក្ខារ ឬសេវាកម្មទាំងឡាយជាមួយក្រុមហ៊ុនក្នុងឬក្រៅប្រទេស ។ អគ្គិសនីកម្ពុជាអាចចុះកិច្ចសន្យា និង កិច្ចព្រមព្រៀងអាជីវកម្មជាមួយភាគីទី ៣ ណាមួយសំរាប់ការផ្តល់ សេវាកម្មអគ្គិសនីរាប់បញ្ចូលទាំងកិច្ច សន្យាជួញដូរថាមពលអគ្គិសនីកិច្ចសន្យាបញ្ជូន និងចែកចាយអគ្គិសនី និងកិច្ចសន្យាសំរាប់សេវាកម្មគ្រប់គ្រង ។

**មាត្រា៣១** : ក្រោយពីការយល់ព្រមរបស់ក្រុមប្រឹក្សាភិបាល អគ្គិសនីកម្ពុជាអាចចូលរួមប្រកបអាជីវកម្ម ឬ ធ្វើវិនិយោគក្នុងក្រុមហ៊ុនដទៃទៀត ។ ក្នុងករណីនេះ អគ្គិសនីកម្ពុជាទទួលខុសត្រូវតែក្នុងកំរិតប្រាក់ហ៊ុនដែលខ្លួនវិនិយោគទៅក្នុងក្រុមហ៊ុននោះប៉ុណ្ណោះ ។

**មាត្រា៣២** : អគ្គិសនីកម្ពុជាមានសិទ្ធិកំណត់លក្ខខ័ណ្ឌការងារសំរាប់បុគ្គលិករបស់ខ្លួនរាប់បញ្ចូលទាំងទឹកប្រាក់បៀវត្ស ប្រាក់ឈ្នួល ប្រាក់បំណាច់ ប្រាក់រង្វាន់ព្រមទាំងកំណត់បញ្ឈប់ការងារ និង វិន័យ ។

**មាត្រា៣៣** : បុគ្គលិកអគ្គិសនីកម្ពុជា មានសិទ្ធិចេញចូលក្នុងបរិវេណដីធ្លី ឬអាគារណាមួយក៏បានដែលជាការចាំបាច់ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួន ។ អនុលោមតាមច្បាប់ អគ្គិសនីកម្ពុជាមានសិទ្ធិ÷

១–តម្លើង ឬជួសជុលខ្សែអគ្គិសនី និងសំភារៈផ្សេងទៀតនៅក្រោម ឬ នៅពីលើដី ឬផ្លូវណា មួយ ។

២–ប្រើប្រាស់ ដីធ្លី អាគារ ផ្លូវ ស្ពាន ឬជញ្ជាំងណាមួយសំរាប់ជាទម្រខ្សែអគ្គិសនី ឬ សំភារៈ ផ្សេងទៀត ។

## ជំពូកទី ៦

## ស្វ័យភាព ហិរញ្ញវត្ថុ

**មាត្រា៣៤** : អគ្គិសនីកម្ពុជាមានសិទ្ធិបើកគណនី ក្នុងធនាគារយកប្រាក់ចេញចូលចាត់ចែងមូលនិធិរបស់ខ្លួន ដើម្បីសំរេចគោលដៅរបស់ក្រុមហ៊ុន និងបំពេញការទទួលខុសត្រូវ និង កាតព្វកិច្ចក្នុងសេវាកម្មរបស់ខ្លួន ។

**មាត្រា៣៥** : អគ្គិសនីកម្ពុជាមានសិទ្ធិចេញ មូលប័ត្រ លិខិតសន្យា លិខិតធានាផ្សេងៗ លិខិតបំណុលស្របតាមប្រព័ន្ធច្បាប់របស់ខ្លួន ព្រមទាំងផែនការក្រុមហ៊ុនដែលបាន

ចែងក្នុងមាត្រា ៤១ នៃអនុក្រឹត្យនេះ ។ ប្រាក់ចំណូលដែលបានមកពីសកម្មភាពទាំងនោះត្រូវប្រើប្រាស់អោយចំគោលដៅដែលក្រុមប្រឹក្សាភិបាលបានអនុម័តដូចដែលមានចែងក្នុងផែនការរបស់ក្រុមហ៊ុន ។

**មាត្រា៣៦** : ក្រោយពីមានការអនុញ្ញាតអំពីមន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋ អគ្គិសនីកម្ពុជាអាចចេញមូលប័ត្រខ្ចីប្រាក់ដែលអាចយកមកប្តូរជាភាគហ៊ុនក្នុងអគ្គិសនីកម្ពុជាបាន ។

**មាត្រា៣៧** : អគ្គិសនីកម្ពុជាត្រូវរៀបចំប្រព័ន្ធហិរញ្ញវត្ថុ និង គណនេយ្យរបស់ខ្លួនស្របតាមច្បាប់ និង បញ្ញត្តិរបស់រាជរដ្ឋាភិបាល ហើយដែលមានលក្ខណៈជាគណនេយ្យអន្តរជាតិ ។

**មាត្រា៣៨** : អគ្គិសនីកម្ពុជាត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុ និង គណនេយ្យនៅរាល់ដំណាច់ឆ្នាំសារពើពន្ធ ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល ព្រមទាំងម្ចាស់ហ៊ុនដទៃទៀតពិនិត្យ ។ អគ្គិសនីកម្ពុជាត្រូវមាន អ្នកត្រួតពិនិត្យបញ្ជីម្នាក់ ដែលមានបទពិសោធន៍គ្រប់គ្រាន់ និង ឯករាជ្យសំរាប់ធ្វើការត្រួត ពិនិត្យប្រចាំឆ្នាំលើសៀវភៅបញ្ជីទាំងឡាយរបស់ក្រុមហ៊ុន ។

**មាត្រា៣៩** : អគ្គិសនីកម្ពុជាមានកាតព្វកិច្ច ក្នុងការបង់ពន្ធដារ បង់អាករព្រមទាំងពន្ធប្រចាំឆ្នាំផ្សេងៗ ដូច គ្នានឹងសហគ្រាសឯកជនដទៃទៀតដែរ ទៅតាមច្បាប់ជាធរមាន ។

## ជំពូកទី ៧

## ទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល

**មាត្រា៤០** : មន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋជាអ្នកកំណត់ទិសដៅនិងបញ្ជាក់គោលការណ៍អគ្គិសនី ស្របតាម នយោបាយអភិវឌ្ឍន៍ជាតិនៃរាជរដ្ឋាភិបាល សំរាប់ដំណើរការអគ្គិសនីកម្ពុជាតាមរយៈបញ្ជា ប្រចាំឆ្នាំជាលាយលក្ខអក្សរចំពោះអ្នកតំណាងរបស់ខ្លួននៅក្នុងក្រុមប្រឹក្សាភិបាល ។ តែបញ្ជានេះពុំត្រូវផ្ទុយនឹងច្បាប់ អនុក្រឹត្យ អាជ្ញាប័ណ្ណ បទបញ្ញត្តិដទៃទៀត និងលក្ខន្តិកៈរបស់អគ្គិសនីកម្ពុជាឡើយ ។

**មាត្រា៤១** : ក្រុមប្រឹក្សាភិបាលរបស់អគ្គិសនីកម្ពុជា ត្រូវអនុម័តរៀងរាល់ឆ្នាំ នូវផែនការរបស់ក្រុមហ៊ុន ដើម្បីដាក់ជូនមន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋជារបាយការណ៍ ។ ផែនការនេះត្រូវចែងអំពីសកម្មភាព ដែលអគ្គិសនីកម្ពុជាត្រូវទទួលរ៉ាប់រងដើម្បីសំរេចទិសដៅនិងភារកិច្ចរបស់ខ្លួន ។

ផែនការក្រុមហ៊ុនមាន ÷

១–ផែនការអភិវឌ្ឍន៍ ប្រចាំថ្ងៃរបស់ក្រុមហ៊ុន និងផែនការវិនិយោគទុនព្រមទាំង សេចក្តីពន្យល់អំពីភាពសមស្របរបស់ផែនការនោះជាមួយកម្មវិធីអភិវឌ្ឍន៍រយៈពេលវែងរបស់អគ្គិសនីកម្ពុជា ។

២–ថវិកាប្រចាំឆ្នាំ ។

៣–តារាងលំអិតកំណត់តម្លៃអគ្គិសនី ដោយផ្អែកលើមូលដ្ឋានតម្លៃដើមទាំងអស់ បូកបញ្ចូល និងប្រាក់ចំណេញសមរម្យ ។

៤–ផែនការកិច្ចព្រមព្រៀងហិរញ្ញវត្ថុដែលក្នុងនោះមានចែងពីបំណុល ការចេញមូលប័ត្រ និងការខ្ចីប្រាក់ចាំបាច់ សំរាប់សកម្មភាពរបស់ក្រុមហ៊ុន ។

៥–ផែនការនៃការគ្រប់គ្រងធនធានទាក់ទងទៅនឹងការថែទាំសំភារៈបរិក្ខារអគ្គិសនី និង

៦–លក្ខណៈវិនិច្ឆ័យ សំរាប់វាយតម្លៃប្រតិបត្តិការអាជីវកម្មរបស់អគ្គិសនីកម្ពុជា ។

**មាត្រា៤២** : អគ្គិសនីកម្ពុជា ត្រូវចុះកិច្ចសន្យាប្រតិបត្តិការអាជីវកម្មជាមួយ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលដែលមានរយៈវេលាអនុវត្តចំនួនពីរឆ្នាំហើយដែលនៅក្នុងនោះត្រូវមានចែងលំអិត អំពីការទទួលខុសត្រូវសេវាកម្ម និងបទដ្ឋាននៃកិច្ចប្រតិបត្តិការសេវាកម្មរបស់អគ្គិសនីកម្ពុជា ។ កិច្ចសន្យានេះត្រូវឆ្លុះបញ្ចាំងនយោបាយថាមពលជាតិ និង ផែនការអភិវឌ្ឍន៍ជាតិ ហើយត្រូវមានលក្ខណៈស្របតាមច្បាប់ និងបទដ្ឋានច្បាប់នានាព្រមទាំងស្របតាមលក្ខន្តិកៈ ក្រុមហ៊ុនផងដែរ ។

**មាត្រា៤៣** : ក្នុងករណីគ្មានការជំទាស់ពីមន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋ អគ្គិសនីកម្ពុជាត្រូវជួល ក្រុមហ៊ុនឯកទេស ដែលគេទទួលស្គាល់នៅលើឆាកអន្តរជាតិ អោយធ្វើអធិការកិច្ចលើការគ្រប់គ្រងរបស់ខ្លួន ៣ ឆ្នាំម្តងៗ ។ ក្រុមប្រឹក្សាភិបាលត្រូវដាក់របាយការណ៍របស់ក្រុមឯកទេសអន្តរជាតិជូនមន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋ និងគណៈរដ្ឋមន្ត្រីពិនិត្យ ។

**មាត្រា៤៤** : អគ្គិសនីកម្ពុជាព្រមផ្តល់សេវាកម្មរបស់ខ្លួនក្នុងតំលៃខាតបង់មួយ លុះត្រាតែមានចុះក្នុងកិច្ច សន្យាប្រតិបត្តិការអាជីវកម្មហើយលុះណាតែរាជរដ្ឋាភិបាល ធ្វើហិរញ្ញប្បទាន ។

**មាត្រា៤៥** : ចាប់ពីអនុក្រឹត្យនេះចូលជាធរមាន និងដោយមានការយល់ព្រមពីមន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋ អគ្គិសនីកម្ពុជាមានសិទ្ធិជាវសេវាកម្មថាមពលអគ្គិសនី បរិក្ខារអគ្គិសនី

អចលនវត្ថុ ឬ ចលនវត្ថុផ្សេងៗ ដែលអគ្គិសនីកម្ពុជាយល់ថាជាការចាំបាច់សំរាប់ប្រកបអាជីវកម្មរបស់ខ្លួន ក្នុងករណីដែលមានការសងទូទាត់តម្លៃឧបករណ៍ទាំងនោះត្រឹមត្រូវតាមច្បាប់ ។

**មាត្រា៤៦** : រាជរដ្ឋាភិបាលអាចធានានូវការខ្ចីបុលដែលចុះកិច្ចសន្យាដោយអគ្គិសនីកម្ពុជា ស្របទៅនឹងច្បាប់ជាធរមាន ស្តីអំពីការចុះកិច្ចសន្យាហិរញ្ញវត្ថុរបស់រដ្ឋ និងធានាសងតែចំពោះឥណទានដែលអគ្គិសនីកម្ពុជាបានខ្ចី ព្រមទាំងការប្រាក់ ក្នុងករណីដែលរដ្ឋបានធានាជាមុន ដោយចំពោះមុខ និងដោយលាយលក្ខអក្សរ ។

**មាត្រា៤៧** : អគ្គិសនីកម្ពុជាត្រូវគោរពតាមបទបញ្ញត្តិនៃច្បាប់ទាំងឡាយដែលស្ថិតនៅជាធរមាននាបច្ចុប្បន្ន និងទៅអនាគត លើកលែងតែករណីផ្ទុយណាដែលមានចែងក្នុងអនុក្រឹត្យនេះ ។

**មាត្រា៤៨** : សំរាប់រយៈពេល ៣ ឆ្នាំ ដំបូងគិតពីថ្ងៃកំណើតនៃក្រុមហ៊ុន ហើយបន្ទាប់ពីពេលនោះតទៅទៀត បើសិនជាមានការឯកភាពរវាងមន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋ ក្រុមហ៊ុនត្រូវមានមន្ត្រីត្រួតពិនិត្យ ហិរញ្ញវត្ថុម្នាក់ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា៤៩** : មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ ÷

ក– ជូនដំណឹងជាលាយលក្ខអក្សរតាមការកំណត់ និងផ្តល់យោបល់ដល់មន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋ ក្រុមប្រឹក្សាភិបាល និងប្រធានអគ្គនាយកអំពីភាពមិនប្រក្រតីផ្សេងៗ ដែលបានកើតឡើង ក្នុងការគ្រប់គ្រងដំណើរការព្រមទាំងគណនេយ្យរបស់ក្រុមហ៊ុន ។

ខ– ដឹកនាំការត្រួតពិនិត្យព្រមទាំងសុំសេចក្តីរាយការណ៍ទាំងឡាយដែលខ្លួនយល់ថាជាការចាំបាច់ដើម្បីតាមពិនិត្យរាល់គណនេយ្យរបស់ក្រុមហ៊ុន សំដៅរ៉ាប់រងអោយគោលដៅផ្នែក ពាណិជ្ជកម្មរបស់ក្រុមហ៊ុនបានសំរេចក្នុងលក្ខណៈស្របច្បាប់ និងស្របតាមលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

គ– បំពេញភារកិច្ចដទៃទៀតដែលច្បាប់ ឬ លក្ខន្តិកៈតំរូវ ឬដែលមន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋផ្ទេរអោយ ។

**មាត្រា៥០** : មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមានសិទ្ធិចូលរួមនៅក្នុងការប្រជុំក្រុមប្រឹក្សាភិបាល តែពុំមានសិទ្ធិបោះឆ្នោតទេ ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ មានសិទ្ធិត្រួតពិនិត្យ

គ្រប់ពេលវេលាលើបណ្ណាបញ្ជីគណនេយ្យ សៀវភៅកំណត់ហេតុ លិខិតឆ្លើយឆ្លង វិក្កយប័ត្រ បញ្ជីចំណាយ និងឯកសារដទៃទៀត របស់ក្រុមហ៊ុន ។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអាចតវ៉ាទៅមន្ត្រីគ្រប់គ្រងហ៊ុនរដ្ឋ និងក្រុមប្រឹក្សាភិបាលរាល់សកម្មភាព ឬអំពើណាមួយដែលខ្លួនយល់ថាផ្ទុយនឹងច្បាប់ឬរំលោភលើលក្ខន្តិកៈរបស់ក្រុមហ៊ុន ។ សំណៅមួយច្បាប់នៃលិខិតតវ៉ានេះត្រូវជូនក្រុមប្រឹក្សាភិបាលក្នុងកំឡុងយ៉ាងយូរ ៣ ថ្ងៃ (ថ្ងៃការងារ) ចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតតវ៉ា ។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រូវរក្សាការសម្ងាត់ចំពោះឯកសារ និងព្រឹត្តិការណ៍ទាំងឡាយណាដែលខ្លួនបានដឹងក្នុងក្របខ័ណ្ឌបេសកម្មរបស់ខ្លួន ហើយក្រៅពីភារកិច្ចដែលបានបញ្ជាក់ក្នុងមាត្រា ៤៩, មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអាចផ្សព្វផ្សាយ ឬ រាយការណ៍នូវសកម្មភាព ឬព្រឹត្តិការណ៍ ទាំងនោះបានតែក្នុងកាលៈទេសៈនិងក្របខ័ណ្ឌដែលច្បាប់អនុញ្ញាត ។

**មាត្រា៥១** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃស្ថាប័នពាក់ព័ន្ធ និង អគ្គិសនីកម្ពុជាមានភារកិច្ចអនុវត្តអោយបានសំរេចនូវអនុក្រឹត្យនេះតាមសមត្ថកិច្ចរៀងៗ ខ្លួន ។

**មាត្រា៥២** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៥៣** : អនុក្រឹត្យនេះត្រូវចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្ថលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ ៨២ អនក្រ.តត**
**ស្ដីពីការតែងតាំងមន្ត្រីរាជការ**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ឯកឧត្ដម ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីព្រះបរមរាជវាំង

**សំរេច**

**មាត្រា ១** : តែងតាំងមន្ត្រីអគ្គនាយកដ្ឋានព្រះបរមរាជវាំង គឺ ÷

- លោក **មាឃ សំអួន** ជាប្រធាននាយកដ្ឋានរដ្ឋបាល
- លោក **គុយ សុផល** ជាប្រធាននាយកដ្ឋានទំនាក់ទំនង
- លោក **ជុំ ចឿន** ជាប្រធាននាយកដ្ឋានអភិរក្ស
- លោក **សូ ស៊ីអឹម** ជាប្រធាននាយកដ្ឋានផែនការ គណនេយ្យ
- លោក **យក់ គុណា** ជាប្រធាននាយកដ្ឋានគ្រប់គ្រងព្រះរាជតំណាក់
- លោក **អ៊ុំ ឯម** ជាប្រធាននាយកដ្ឋានឧបត្ថម្ភ នឹងសង្គ្រោះប្រជារាស្ត្រ

**មាត្រា ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រី

ព្រះបរមរាជវាំង និងអស់លោកក្នុងមាត្រា ១ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗ ខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ ៤៣ អនក្រ.តត**

**ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

**សំរេច**

**មាត្រា ១** : ផ្ទេរលោក **អ៊ុំ លៀវខាតិ** អគ្គទីប្រឹក្សាស្ថានឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជានៅញុងយ៉ាងអោយមកបំរើការងារក្នុងប្រទេស និង លុបតំណែងអគ្គទីប្រឹក្សាស្ថានទូតនៅក្រុងព្យុងយ៉ាងចេញ ។

**មាត្រា ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង

ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ លោក **អ៊ី សៀវជាតិ** ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្ថលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៦

## អនុក្រឹត្យលេខ ៨៤ អនក្រ.តត
## ស្តីពីការតម្លើងឋានន្តរសក្តិ ជាកិច្ចបច្ឆាមរណៈ

* * *

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និង អគ្គសេនាធិការ នៃកងទ័ពជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុង កម្ពុជាធិបតី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

**សំរេច**

**មាត្រា ១** : ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក**ជាកិច្ចបច្ឆាមរណៈជូនចំពោះសព ÷

–លោកវរសេនីយ៍ទោ **ម៉ូ ផេន** អត្តលេខ ០០០៨៦៣

នាយសេនាធិការតំបន់ប្រតិបត្តិការសឹករង កណ្តាល

**មាត្រា ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ នៃ កងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១
ព្រះហស្តលេខានិងត្រា
**នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខានិងត្រា
**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ ៨៥ អនក្រ.តត**

**ស្តីពីការតម្លើងឋានន្តរសក្តិ ជាកិច្ចបច្ឆាមរណៈ**

* * *

**រាជរដ្ឋាភិបាល**

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាអធិបតី ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ១៩៩៣ ស្តីពី ការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត ក្រសួងការពារជាតិ និងអគ្គសេនាធិការនៃកងទ័ពជាតិ

-យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

**សំរេច**

**មាត្រា ១** : ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរសេនីយ៍ឯក**ជាកិច្ចបច្ឆាមរណៈជូនចំពោះសព ÷

-លោក វរសេនីយ៍ទោ **ឃោ ម៉ុនឃាន** អត្តលេខ ០០១០៣៧ មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងប៉ៃលិន

**មាត្រា ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ នៃ កងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានច្បាប់ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទិ ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៦

## អនុក្រឹត្យលេខ ៨៦ អនក្រ.តត

## ស្តីពីការកែសំរួលឋានន្តរសក្តិ នាយទាហាន

* * *

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ១៩៩៣

ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២នៃរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និង អគ្គសេនាធិការ នៃកងទ័ពជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

**សំរេច**

**មាត្រា ១ :** ត្រូវបានកែសំរួលឋានន្តរសក្តិ នាយទាហាន ថ្នាក់**ឧត្តមសេនីយ៍ឯក**ក្នុងកងយោធពលខេមរភូមិន្ទ ÷

១-លោក **ហ៊ីង ស្រេង** ជានាយសេនាធិការរង យោធភូមិភាគទី ៣

២-លោក **សុត្រា ស៊ីយ** ជាមេបញ្ជាការរង កងពលធំលេខ ១

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| --- | --- |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ ៤៧ អនក្រ.តត**

**ស្តីពីការតម្លើងឋានន្តរសក្តិ នាយទាហាន**

* * *

## រាជរដ្ឋាភិបាលកម្ពុជា

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី២៤ ខែ កក្កដា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត ក្រសួងការពារជាតិ និងអគ្គសេនាធិការ នៃកងទ័ពជាតិកម្ពុជា

– យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

### សំរេច

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរសក្តិ នាយទាហាន ថ្នាក់**វរសេនីយ៍ឯក**ក្នុងកងយោធពលខេមរភូមិន្ទ ÷

១–លោកវរសេនីយ៍ទោ **ថោង ឫទ្ធិ** អត្តលេខ ០០១០៩១
មេបញ្ជាការការពារផ្ទាល់ សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១

២–លោកវរសេនីយ៍ទោ **ម៉ក់ សុខន** អត្តលេខ ០០១០៩៧
មេបញ្ជាការការពារផ្ទាល់ សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១

៣–លោកវរសេនីយ៍ទោ **ចៅ គុណ** អត្តលេខ ០០១០៩៨
មេបញ្ជាការការពារផ្ទាល់សម្តេចនាយករដ្ឋមន្ត្រីទី ២

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ និង សាម៉ីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូល ជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ ៤៨ អនក្រ.គត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយអោយ ប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.១០៩៥.០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការ បង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

**សំរេច**

**មាត្រា ១** : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិតាមលំដាប់ថ្នាក់ជូនចំពោះសប្បុរសជន និង ក្រុមហ៊ុន ដែលបានជួយឧបត្ថម្ភថវិកា សំរាប់រៀបចំពិព័រណ៍ពាណិជ្ជកម្មកម្ពុជា ៩៦ ដូចមានរាយនាមខាងក្រោម នេះ ÷

ក/–មេដាយមាស :

| | | | |
|---|---|---|---|
| ១–លោក ឧកញ៉ា **ថេង ប៊ុនម៉ា** | | ទឹកប្រាក់ | ១០.០០០$ |
| ២–លោក ឧកញ៉ា **គង់ ទ្រឹង** | | ទឹកប្រាក់ | ១០.០០០$ |

ខ/–មេដាយប្រាក់ :

| | | | |
|---|---|---|---|
| ១–អ្នកស្រី **ឈឹម ម៉េងហួរ** | ក្រុមហ៊ុន ATT WOOD | ទឹកប្រាក់ | ៥.០០០$ |

គ/–មេដាយសំរិត :

| | | | |
|---|---|---|---|
| ១–**គី នីតា** | ក្រុមហ៊ុនស្រ៊ុនស្រ៊ុន | ទឹកប្រាក់ | ៣.០០០$ |

២–ក្រុមហ៊ុនស្រាបៀរអង្គរ ទឹកប្រាក់ ៣.០០០$

៣–លោក ផៃ ហុកឈួន ក្រុមហ៊ុនលីហេងគ្រុប ទឹកប្រាក់ ២.០០០$

៤–លោកជំទាវ ឈុន លាង ក្រុមហ៊ុនវឌ្ឍនៈ ទឹកប្រាក់ ២.០០០$

៥–លោកឧកញ៉ា ម៉ិនឈួយស្រ៊ុម ក្រុមហ៊ុនសុភគារខ្មែរទឹកប្រាក់ ២.០០០$

៦–លោក លឹម ហេង ក្រុមហ៊ុន លឹម ហេង ទឹកប្រាក់ ២០០០$

៧–លោក ឆេង យាង ក្រុមហ៊ុន ឆេង យាង ទឹកប្រាក់ ២.០០០$

៨–លោក គង់ ហុង ក្រុមហ៊ុន គង់ ហុង ទឹកប្រាក់ ២.០០០$

៩–លោក ជួង ឈើង ក្រុមហ៊ុន ជួង ឈើង ទឹកប្រាក់ ២.០០០$

១០–ក្រុមហ៊ុនកាំបូឌីយ៉ាម៉ាកឺធីញ ទឹកប្រាក់ ២.០០០$

១១–លោក ឡៅ គឹមគុង ក្រុមហ៊ុនពិភពពាណិជ្ជ ទឹកប្រាក់ ២.០០០$

១២–លោក ស៊ុន ស៊ាងហួត ក្រុមហ៊ុនស៊ុនស៊ីម៉ិចកូ ទឹកប្រាក់ ២.០០០$

១៣–ក្រុមហ៊ុន SHELL Cambodia ទឹកប្រាក់២.០០០$

១៤–លោកឧកញ៉ា ស្រី លាងឈាង ក្រុមហ៊ុនជីម៉ិច ទឹកប្រាក់២.០០០$

១៥–លោក ឡុច សារ៉េត ក្រុមហ៊ុនវិញលី ទឹកប្រាក់២.០០០$

១៦–ក្រុមហ៊ុន DUNHILL ទឹកប្រាក់២.០០០$

១៧–ក្រុមហ៊ុន Brother ទឹកប្រាក់២.០០០$

១៨–ក្រុមហ៊ុន COLEXIM ទឹកប្រាក់២.០០០$

១៩–ក្រុមហ៊ុន North EAST LUMBER ទឹកប្រាក់២.០០០$

២០–ក្រុមហ៊ុន CASOTIM ICOM 05 គ្រឿង

**មាត្រា ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្ថលេខានិងត្រា ហត្ថលេខានិងត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ ៨៩ អនក្រ.គត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.១០៩៥.០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

**សំរេច**

**មាត្រា ១ :** ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិ ជូនចំពោះសប្បុរសជន តៃវ៉ាន់ ចំនួន ០៣ រូប ដែលបានបរិច្ចាគអំណោយជាអង្ករ ម៉ាស៊ីនបូមទឹក និង ថវិកា គិតជាទឹកប្រាក់សរុប ១៥០.០០០ ដុល្លារអាមេរិក ថ្វាយសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ សំរាប់ចែកជូនប្រជារាស្ត្រដែលជួបការលំបាកខ្វះខាត ដូចមានរាយនាមខាងក្រោមនេះ

១-លោក SHIH CHIN HSIN

២-លោក STEVE S. UNG

៣-លោក TSENG CHIH PING

**មាត្រា ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនាត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៦

## អនុក្រឹត្យលេខ ៩០ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.១០៩៥.០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តស្វាយរៀង

## សំរេច

**មាត្រា ១** : ត្រូវបានប្រគល់មេដាយ ស្ថាបនាជាតិ ជូនចំពោះសប្បុរសជន ដែលបានបរិច្ចាគថវិកាកសាងសាលាបឋមសិក្សា **នរោត្តម រណឫទ្ធិ** នៅក្នុងឃុំចេក ស្រុក

ស្វាយជ្រុំ ខេត្តស្វាយរៀង ដូចមានរាយនាម ខាងក្រោមនេះ

ក–ជូនមេដាយប្រាក់ស្ថាបនាជាតិ ចំពោះមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋាន អធិការកិច្ច ដែលបានបរិច្ចាគប្រាក់ ចំនួន ៦.០០០ ដុល្លារអាមេរិក ។

ខ–ជូនមេដាយសិរីស្ថាបនាជាតិចំពោះ ÷

១–ឯកឧត្តម **ផុន សុផល** បរិច្ចាគប្រាក់ ២.០០០ ដុល្លារអាមេរិក

២–លោក **ម៉ុខ ឫទ្ធី** បរិច្ចាគប្រាក់ ២.០០០ ដុល្លារអាមេរិក

**មាត្រា ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៦

## អនុក្រឹត្យលេខ ៩១ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

### រាជរដ្ឋាភិបាល

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែល

ប្រកាសអោយអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

–បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.១០៩៥.០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

–តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ

**សំរេច**

**មាត្រា ១** : ត្រូវបានប្រគល់មេដាយ សិរីវុឌ្ឍ ស្ថាបនាជាតិជូនចំពោះលោក **គ្រាល ហេង** និង ភរិយា ដែលបានបរិច្ចាគទឹកប្រាក់ចំនួន ១.៣០០ ដុល្លារអាមេរិក សំរាប់កសាងអាគារសិក្សា ០១ខ្នង នៅសាលាបឋមសិក្សាបឹងត្របែកខាងកើត រាជធានី ភ្នំពេញ ។

**មាត្រា ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៩៦

## អនុក្រឹត្យលេខ ៩២ អនក្រ.តត
## ស្តីពីការតែងតាំងទីប្រឹក្សារបស់ឯកឧត្តម
## ហុង ស៊ុនហួត ក្នុងឋានៈជារដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

* * *

## រាជរដ្ឋាភិបាលកម្ពុជា

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង ទី ២

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត. ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក.ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- **តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**សំរេច**

**មាត្រា ១ :** ត្រូវបានតែងតាំង លោកស្រី **អ៊ុងត្រាក់ កន្លាផាវី** ជាទីប្រឹក្សារបស់ឯកឧត្តម **ហុង ស៊ុនហួត** ក្នុង ឋានៈជារដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ។

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និង ប្រធានស្ថាប័នពាក់ព័ន្ធ និង សាម៉ីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

# ២—សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៦

## សេចក្តីសំរេចលេខ ១៦ សសរ

## ស្តីពីការបង្កើតគណៈកម្មការសំរាប់រុករក និងជួយសង្គ្រោះយន្តហោះ និងនាវាពេលមានឧប្បត្តិហេតុ

* * *

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណា ចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើរបស់ឯកឧត្តមអនុរដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

## សំរេច

**ប្រការ ១** : ត្រូវបានបង្កើតគណៈកម្មការមួយសំរាប់រុករក និងសង្គ្រោះយន្តហោះ និងនាវាពេលមានឧប្បត្តិហេតុ ដែលមានសមាសភាពដូចតទៅ ÷

១_ឯកឧត្តម **ចាយ សាំងយ៉ុន** សហរដ្ឋលេខាធិការក្រសួងការពារជាតិ ជាសហប្រធាន

២_ឯកឧត្តម **ឯក សេរីវឌ្ឍន៍** សហរដ្ឋលេខាធិការក្រសួងការពារជាតិ ជាសហប្រធាន

៣_ឯកឧត្តម **ហូ សុខ** សហរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធាន

៤_ឯកឧត្តម **ង៉ែម សំអាន** សហរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធាន

៥_ឯកឧត្តម **ត្រាំ អ៊ីវតឹក** រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន ជាសមាជិក

៦_ឯកឧត្តម **ឈោ សុខ** រដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ជាសមាជិក

៧_ឯកឧត្តម **ឌី ណារ៉ុងរិទ្ធ** រដ្ឋលេខាធិការក្រសួងសុខាភិបាល ជាសមាជិក

៨_ឯកឧត្តម **សូ ឃុន** រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ជាសមាជិក

៩_ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋលេខាធិការក្រសួងពត៌មាន ជាសមាជិក

១០_ឯកឧត្តម **ម៉ុក សំអុល** អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ជាសមាជិក

១១_ឯកឧត្តម **កែវ សាផល** អគ្គនាយកនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ជាសមាជិក

១២_ឯកឧត្តមបណ្ឌិត **ចែម ពិឌ្យា** អគ្គលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក

**ប្រការ ២** : គណៈកម្មការនេះមានភារកិច្ចដូចតទៅ ÷

_រុករក និងជួយសង្គ្រោះយន្តហោះ និងនាវា ភ្ញៀវអ្នកដំណើរ និងសំភារៈនៅពេលដែលយន្តហោះ និងនាវាគ្រប់ប្រភេទ មានគ្រោះថ្នាក់ ។

_សំរបសំរួល និងទំនាក់ទំនងរវាងក្រសួង រដ្ឋលេខាធិការដ្ឋាន និងខេត្ត_ក្រុងពាក់ព័ន្ធដើម្បី ជំរុញការសហការជួយរុករកសង្គ្រោះយន្តហោះនិងនាវាពេលមានគ្រោះថ្នាក់ ។

_រៀបចំមជ្ឈមណ្ឌលប្រចាំការនិងផ្តល់ពត៌មាន ស្តីអំពីឧប្បត្តិហេតុនៃយន្តហោះនិងនាវា ។

- គណៈកម្មការនេះ ត្រូវប្រជុំបែងចែកភារកិច្ចជាក់ស្តែង និងរិះរកវិធានការថែម ទៀតដើម្បីដំណើរការរុករកសង្គ្រោះយន្តហោះ និងនាវាអោយមានប្រសិទ្ធភាព ។
- រាល់សកម្មភាពរុករកសង្គ្រោះយន្តហោះ និងនាវាពេលមានឧប្បត្តិហេតុគណៈកម្មការត្រូវសរុបរបាយការណ៍ ព្រមទាំងការចំណាយផ្សេងៗ ក្នុងពេលចុះបំពេញបេសកកម្ម ដើម្បីដាក់ជូនរាជរដ្ឋាភិបាលជ្រាប និង សំរេច ។
- គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការពារជាតិ ។

**ប្រការ ៣** : សេចក្តីសំរេចលេខ៨៩ សសរ ចុះថ្ងៃទី ២៥-១២-១៩៩៥ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការសំរាប់រុករកជួយសង្គ្រោះយន្តហោះពេលមានឧប្បត្តិហេតុ ចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ គ្រប់ក្រសួង និងគ្រប់រដ្ឋលេខាធិការដ្ឋានដែលមានការពាក់ព័ន្ធ និងបណ្តាឯកឧត្តមដែលមាននាមក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

ភ្នំពេញ,ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ១៩៩៦

**សេចក្តីសំរេចលេខ ១៧ សសរ**

**ស្តីពីគណៈកម្មការរៀបចំការអនុម័ត រាល់វិធាន**

**ការការពារបេតិកភ័ណ្ឌស្ថាបត្យកម្ម និងនគររោប**

**នីយកម្ម នៃទីក្រុងភ្នំពេញ**

* * *

## រាជរដ្ឋាភិបាល

_បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រមលេខ នស.រកម ០១៩៦_២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌

_បានឃើញព្រះរាជក្រមលេខ ០៤ នស.៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំទឹកដីនគរូបនីយកម្ម និង សំណង់

_បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកាឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញព្រះរាជក្រឹត្យលេខ នស.រកត. ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

_ផ្អែកតាមតម្រូវការចាំបាច់

## សំរេច

**ប្រការ ១** : បង្កើតគណៈកម្មការរៀបចំអោយការអនុម័ត ( កំណត់ ) រាល់វិធានការការពារបេតិកភ័ណ្ឌ ស្ថាបត្យកម្ម និងនគរូបនីយកម្មនៃទីក្រុងភ្នំពេញ ។

**ប្រការ ២** : គណៈកម្មការនេះរួមមាន :

**ក)_ផ្នែកមន្ត្រីអាជ្ញាធរ :**

| | | | |
|---|---|---|---|
| ១_ឯកឧត្តម | **វណ្ណ មូលីវណ្ណ** | ទេសរដ្ឋមន្ត្រីនិងជាអនុប្រធានក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ | ប្រធាន |
| ២_ឯកឧត្តម | **ឈឹម សៀកឡេង** | ប្រតិភូតំណាងរាជរដ្ឋាភិបាលប្រចាំទីក្រុងភ្នំពេញ | ជាអនុប្រធាន |
| ៣_ឯកឧត្តម | **គ្រឿយ បេងហុង** | អភិបាលរងរាជធានីភ្នំពេញ | ជាសមាជិក |

៤_លោក **ឌី យ៉ាវ** នាយកការិយាល័យកិច្ចការនគររោបនីយកម្ម ជាលេខា

៥_លោក **ជុំប តៀន** តំណាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ព្រឹទ្ធបុរសមហាវិទ្យាល័យបូរាណវិទ្យា ជាសមាជិក

៦_លោក **ឈួន សុធី** នាយកមន្ទីរសុរិយោដីក្រុងភ្នំពេញ ជាសមាជិក

៧_លោក **យស់ ឆោមវ៉ាន់ឌី** អនុប្រធានមន្ទីរនគររោបនីយកម្មនិងសំណង់ទីក្រុងភ្នំពេញ ជាសមាជិក

៨_អ្នកស្រី **ញាណ ចំណុល** អនុប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈទីក្រុងភ្នំពេញ ជាសមាជិក

**ខ)_ផ្នែកឥស្សរៈជន**

១_សម្តេចរាជបុត្រ ព្រះរៀម **នរោត្តម បុប្ផាទេវី**

២_ឯកឧត្តម **គង់ សំអុល**

៣_ឯកឧត្តម **ឆេង ផុន**

៤_ឯកឧត្តម **ឃី តាំងលីម**

៥_ព្រះសង្ឃរាជ **ទេព វង្ស**

**ប្រការ ៣** : គណៈកម្មការនេះមានភារកិច្ចដូចតទៅ :

១_កសាងនិងលើកបញ្ជីសំណើនូវបណ្តាអាគារ និងរមណីយដ្ឋានក្នុងទីក្រុងភ្នំពេញ ដើម្បីសំរេចកំណត់បញ្ចូលក្នុងបញ្ជីអាគារសម័យបុរាណស្របតាមច្បាប់ ស្តីពីបេតិកភ័ណ្ឌវប្បធម៌ជាតិដោយផ្អែកលើបញ្ជីសារពើភ័ណ្ឌអាគារ និង រមណីដ្ឋានដែលរៀបចំដោយការិយាល័យនគររោបនីយកម្ម ។

២_លើកយោបល់អំពីបែបបទពិនិត្យសិក្សា នៃច្បាប់អនុញ្ញាតសាងសង់ជាយថាប្រភេទចំពោះអាគារទាំងនោះ សំដៅធានាគារថែទាំនិងការជួសជុលស្ថារ ព្រមទាំងមធ្យោបាយត្រួតពិនិត្យដល់ទីកន្លែង សំដៅ ការពារនិងថែទាំនូវរមណីដ្ឋានទាំងឡាយ

ដែលបានកំណត់រួចហើយ ។

៣_បំផុសនិងលើកទឹកចិត្តរាល់គំនិតថៃទាំបេតិកភ័ណ្ឌ ព្រមទាំងរាល់ការងារស្វែង យល់អំពីបេតិកភ័ណ្ឌនោះ ។

**ប្រការ ៤** : បណ្តាសមាជិកគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញនិងក្រោមការដឹកនាំរបស់ប្រធាន ។

**ប្រការ ៥** : សាលាក្រុងភ្នំពេញ អគ្គលេខាធិការដ្ឋានរដ្ឋសភាជាតិ អគ្គលេខាធិការដ្ឋានព្រះបរមរាជវាំង ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងធម្មការ ក្រសួងសាធារណការនិងដឹកជញ្ជូន មហាវិទ្យាល័យស្ថាបត្យកម្មនិងនគរោបនីយកម្ម មហាវិទ្យាល័យបូរាណវិទ្យា មន្ទីរនគរោបនីយកម្មនិង សំណង់ មន្ទីរស៊ីវិលយោធីក្រុង ការិយាល័យកិច្ចការនគរោបនីយកម្ម ព្រមទាំងសាមីជនដូចមានចែងក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានិងចុះហត្ថលេខានេះតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

# III ការងារបណ្តាក្រសួង

## ១—ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

**ប្រកាស**

ភ្នំពេញ,ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៨៦

**ប្រកាសលេខ ៣៤៩ ឧក. ប្រក**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល**

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
– បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/៩៥ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ១៩៩៦
– បានឃើញលិខិតលេខ ២៧៣/៩៦ គ.វិ.ក ចុះថ្ងៃទី ០១–៣–១៩៩៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
– បានឃើញលិខិតលេខ ១០៧៥ លអស ចុះថ្ងៃទី ០៦–៤–១៩៩៦ របស់សាលាក្រុងភ្នំពេញស្តីពីការអនុញ្ញាតអោយសាងសង់រោងចក្របារី
– យោងពាក្យស្នើរបស់ក្រុមហ៊ុនយូតាយឡុង តូបាកូ ប្រូដាក់ ចុះថ្ងៃទី ៣០–៤–១៩៩៦

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយក្រុមហ៊ុន យូតាយឡុង តូបាកូ ប្រូដាក់ (*YUETAILONG TOBACCO PRODUCT.CoLTD*) តំណាងដោយលោក ចាវ វេ វេ ជនជាតិចិន ភេទប្រុស អាយុ ៣៨ ឆ្នាំ អាស័យដ្ឋានផ្ទះលេខ ២០៦ មហាវិថីព្រះសីហនុ សង្កាត់បឹងកេងកង ២ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កាន់អត្តសញ្ញាណប័ណ្ណលេខ៣៦៩១៤៣ភពចុះថ្ងៃទី ០៩–៨–១៩៩៤ បង្កើតរោងចក្រផលិតបារីនាំចេញ ដែលមានឈ្មោះថា « រោងចក្របារី យូតាយឡុង »មានទីតាំង នៅផ្លូវលេខ ២៧១ សង្កាត់ទឹកល្អក់ទី ៣ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។

**ប្រការ ២** : ការសាងសង់និងរៀបចំគ្រឿងចក្រត្រូវធ្វើទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អោយបានសំរេចក្នុងរយៈពេល ៩ ខែ ដោយរាប់បញ្ចូលទាំងរយៈពេលដំណើរការសាកល្បងផង ។

**ប្រការ ៣** : ក្នុងកិច្ចដំណើរការក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្មធានាការពារបរិស្ថាន និងគុណភាពផលិតផលហើយត្រូវធ្វើរបាយការណ៍ ប្រចាំខែជូនក្រសួងឧស្សាហកម្ម រ៉ែនិងថាមពលអំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

**ប្រការ ៤** : រោងចក្រនេះត្រូវបានអនុញ្ញាអោយផលិតនូវមុខផលិតផល« បារី »ទៅតាមគំរូនិងផ្លាកសញ្ញាដែលតំកល់ទុកនៅក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ។

**ប្រការ ៥** : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសប្រការណាមួយដែលបានចែងខាងលើប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

**ប្រការ ៦** : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និងលោក ចាវ វេ រ៉េ ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀង ៗ ខ្លួន ។

**ប្រការ ៧** : ប្រកាសនេះមានអនុភាព គតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ពូ សុធីរៈ**

* * *

ភ្នំពេញ,ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៩៦

## ប្រកាសលេខ ៣៥០ បឈ.ប្រក
## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ១៩៩៦
- យោងកំណត់ហេតុកិច្ចប្រជុំអន្តរក្រសួង ស្តីពីកាងារអាស៊ាន ថ្ងៃទី ០៧-៥-១៩៩៦ នៅក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- ពិនិត្យសំណូមពរការងាររបស់ក្រសួង

**សំរេច**

**ប្រការ ១** : បង្កើតការិយាល័យមួយឈ្មោះ ការិយាល័យកិច្ចការអាស៊ាន ស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានផែនការ ។

**ប្រការ ២** : តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់ការិយាល័យនេះ អាស្រ័យដោយថ្នាក់ដឹកនាំនាយកដ្ឋានផែនការ កំណត់និងបានការឯកភាពពីថ្នាក់ដឹកនាំក្រសួង ។

**ប្រការ ៣** : លោកប្រធានមន្ទីរ លោកប្រធាននាយកដ្ឋានបុគ្គលិក លោកប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញកិច្ច លោកប្រធាននាយកដ្ឋានផែនការ និងអស់លោកប្រធាននាយកដ្ឋានពាក់ព័ន្ធមានបន្ទុករៀង ៗ ខ្លួនអនុវត្តប្រកាសនេះ ។

**ប្រការ ៤** : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**តៅ សុធីរ:**

* * *

## ២—ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## ប្រកាស

**ប្រកាសលេខ: ២៨៨ ប្រក.កសក**

**ស្តីពីការអនុញ្ញាតអោយបង្កើតរោងចក្រកែច្នៃជលផល**

**របស់ក្រុមហ៊ុន *CAMBODIA-THAI MARINE PRODUCTS CO . LTD***

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រ កម្ពុជា

– បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៦_៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
– បានឃើញក្រឹត្យច្បាប់លេខ ៣៣ ក្រ.ច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្ដីពីការគ្រប់គ្រងវិស័យជលផល
– បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៨៤ ស្ដីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម
– បានឃើញប្រកាសលេខ ០០០២ ប្រក.កសក ចុះថ្ងៃទី ១០ ខែមករាឆ្នាំ ១៩៨៩ របស់ក្រសួងកសិកម្ម ស្ដីពីអង្គការមានសមត្ថកិច្ច ចេញលិខិតអនុញ្ញាតអោយធ្វើអាជីវកម្ម ក្នុងដែននេសាទ វារីវប្បកម្មកែច្នៃជលផល និង ការអនុញ្ញាតពិសេស
– បានឃើញលិខិតលេខ ៤១២/៩៥ គ.វិ.ក ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៩៥ និងលិខិតលេខ ៤៤៣/៩៥ គ.វិ.ក របស់គណៈកម្មាធិការវិនិយោគកម្ពុជា ស្ដីពីការសំរេចយល់ព្រមអោយអនុវត្តគំរោងវិនិយោគ ផ្នែកបង្កើតរោងចក្រផលិតអាហារត្រី និងស្ដីពីការសំរេចឯកភាពជាគោលការណ៍អោយបង្កើតក្រុមហ៊ុនវិនិយោគឈ្មោះ *CAMBODIA-THAI MARINE PRODUCTS CO.LTD*
– បានឃើញចំណារឯកភាពរបស់អភិបាលក្រុងព្រះសីហនុលេខ ៧៥ អក.កសន ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦
– តាមសំណើរបស់ប្រធាននាយកដ្ឋានជលផល

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយក្រុមហ៊ុន *CAMBODIA-THAI MARINE PRODUCTS CO.LTD* បង្កើតរោងចក្រកែច្នៃជលផល ( ម្សៅត្រី ) មួយកន្លែងនៅមណ្ឌល ០១ សង្កាត់ ០១ ខ័ណ្ឌ មិត្តភាព ក្រុងព្រះសីហនុ តាមគំរូប្លង់មានភ្ជាប់ នឹងប្រកាសនេះ ។

**ប្រការ ២** : ការបញ្ចូល_បញ្ចេញផលិតផលជលផលត្រូវមានសៀវភៅស្ថិតិកត់ត្រាជារៀងរាល់ថ្ងៃប្រចាំរោងចក្រ ។

**ប្រការ ៣** : រាល់ការដឹកជញ្ជូនផលិតផលជលផល សំរាប់នាំចេញទៅបរទេស និង គ្រប់សកម្មភាពការ ងារផ្សេង ៗ ទៀតដែលទាក់ទងដល់សមត្ថកិច្ចជលផល ត្រូវអនុវត្តអោយបានត្រឹមត្រូវតាម ក្រឹត្យច្បាប់លេខ ៣៣ ក្រច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ

១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល ។

**ប្រការ ៤** : ប្រកាសអនុញ្ញាតបង្កើតរោងចក្រកែច្នៃជលផល ( ម្សៅត្រី ) នេះ ត្រូវទុកជានិរាករណ៍ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្នុងករណីដែលយល់ឃើញថា ការចាំបាច់ ឬ បានប្រព្រឹត្តអំពើល្មើសជលផលធ្ងន់ធ្ងរ ។

**ប្រការ ៥** : អគ្គនាយកក្រសួង ប្រធានមន្ទីរក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធាននាយកដ្ឋាន ផែនការស្ថិតិ ប្រធាននាយកដ្ឋានផែនការគណនេយ្យ-ហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការត្រួតពិនិត្យ ប្រធាននាយកដ្ឋានជលផល ប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទ ប្រធានការិយាល័យជលផលក្រុងព្រះសីហនុ និងសាមិជនត្រូវទទួលបន្ទុករៀង ៗ ខ្លួន អនុវត្តប្រកាសនេះ ។

**ប្រការ ៦** : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

រដ្ឋលេខាធិកា

ហត្ថលេខានិងត្រា

**ឈាវ សុខ**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ១៩៩៦

## ប្រកាសលេខ ៣១៣ ប្រក.កសក.ចត

## ស្តីពីការបង្កើតសួនសត្វ

* * *

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ១០៩៤.៨៣ នស.រកត ចុះថ្ងៃទី ២៤ ខែ តុលា

ឆ្នាំ ១៩៨៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៨៤ ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម

- បានឃើញសេចក្តីសំរេចលេខ ៦០៨ ចត.កសក ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ១៩៨៦ ស្តីពីការកំណត់តួនាទីភារកិច្ច និងអង្គការចាត់តាំងរបស់នាយកដ្ឋានរុក្ខាប្រមាញ់
- តាមសំណើរបស់នាយកដ្ឋានរុក្ខាប្រមាញ់

**សំរេច**

**មាត្រា ១** : បង្កើតសួនសត្វមួយកន្លែងមានឈ្មោះថា សួនសត្វភ្នំតាម៉ៅ ស្ថិតនៅក្នុងឃុំ ក្រាំងធ្នង់ ស្រុក បាទី ខេត្ត តាកែវ ។

**មាត្រា ២** : សួនសត្វភ្នំតាម៉ៅជាផ្នែកមួយនៅក្នុងការិយាល័យ ការពារសត្វព្រៃនៃនាយកដ្ឋានរុក្ខាប្រមាញ់។

**មាត្រា ៣** : ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តិទៅរបស់សួនសត្វភ្នំតាម៉ៅ អាស្រ័យដោយប្រធាននាយកដ្ឋានរុក្ខាប្រមាញ់កំណត់សំរេច ។

**មាត្រា ៤** : សួនសត្វភ្នំតាម៉ៅគ្រប់គ្រងដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការ ។

**មាត្រា ៥** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦** : អគ្គនាយកក្រសួង ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋាន គណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងប្រធាននាយកដ្ឋានរុក្ខាប្រមាញ់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀង ។ ខ្លួន ចាប់ពីថ្ងៃចុះ ហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

**ឈា សុខ**

* * *

## ៣—ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

## ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ១៩៩៦

### ប្រកាសលេខ ១២០/៩៦ ពម.មព/ប្រក
### អនុញ្ញាតអោយកាសែតឈ្មោះ « គំនិតកូនខ្មែរ »
### បោះពុម្ពចែកផ្សាយ

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី ៤១
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស.រកម. ០៨៩៥–០៧ ចុះថ្ងៃទី ០១ កញ្ញា ១៩៩៥
- បានឃើញសំណើសុំបោះពុម្ពកាសែត « គំនិតកូនខ្មែរ » ចុះថ្ងៃទី ១០ មីនា ឆ្នាំ ១៩៩៦

### សំរេច

**ប្រការ ១** : អនុញ្ញាតអោយកាសែតឈ្មោះ « គំនិតកូនខ្មែរ » បោះពុម្ពចែកផ្សាយដោយមានលោក **ចេង សុខណា** ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់លេខ ០១ ក្រុម ៤៩ សង្កាត់មិត្តភាព ខ័ណ្ឌ ៧ មករា ក្រុងភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរចំណុចណាមួយក្នុងអត្តសញ្ញាណនៃកាសែតរបសខ្លួនត្រូវជូនដំណឹងជាមុន ០៥ ថ្ងៃមកក្រសួងពត៌មាន ដើម្បីរង់ចាំសេចក្តីសំរេចជា ថ្មី ។

**ប្រការ ២** : រាល់ដំណើរការបោះពុម្ពចែកផ្សាយ ត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌អ្នកកាសែត និង ឈរលើស្មារតីទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារអត្ថបទត្រូវអនុវត្តអោយបានសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់នៃ

ព្រះរាជាណាចក្រកម្ពុជា រួចស្នើប្រគល់កាសែតចំនួន ០៦ ច្បាប់រៀងរាល់លេខចេញផ្សាយ មកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

**ប្រការ ៣** : ក្នុងករណីប្រព្រឹត្តអំពីសេចក្តីដូចមានចែងក្នុងប្រការ ១ និងប្រការ ២ ខាងលើ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៤** : អគ្គនាយក រដ្ឋបាល និង ហិរញ្ញវត្ថុ–នាយកមណ្ឌលពត៌មាន និងលោកចាងហ្វាងកាសែត « គំនិតកូនខ្មែរ » ត្រូវអនុវត្តនូវប្រកាសនេះ ។

**ប្រការ ៥** : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

**ខៀវ កាញារីទ្ធ**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ១៩៩៦

## ប្រកាសលេខ ១២១/៩៦ ពម.មព/ប្រក
## អនុញ្ញាតអោយផ្ទេរសិទ្ធិចាងហ្វាងការផ្សាយកាសែត
## « សម្លេងនិស្សិត » បោះពុម្ពចែកផ្សាយ

* * *

– បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី ៤១

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា

– បានឃើញច្បាប់ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស.រកម ០៨៩៥–០៧ ចុះថ្ងៃទី ០១ កញ្ញា ១៩៩៥

–បានឃើញសំណើចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ១៩៩៦ សុំប្តូរចាងហ្វាងការផ្សាយ របស់កាសែត « សម្លេងនិស្សិត » ពីអ្នកស្រី **ជួន រ៉ានី** មកលោក **កែវ សោភ័ណ** វិញ ។

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយផ្ទេរសិទ្ធិ ចាងហ្វាងការផ្សាយកាសែត «សម្លេងនិស្សិត» ពីអ្នកស្រី **ជួន រ៉ានី** មកលោក **កែវ សោភ័ណ** ចាងហ្វាងកាសែត «ចក្រវាឡ» វិញ ។ ទីស្នាក់ការលេខ ០៨ ក្រុមទី ០៦សង្កាត់ទំនប់ទឹក ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរនូវចំណុចណាមួយក្នុងអត្តសញ្ញាណនៃសារពត៌មានរបស់ខ្លួន ត្រូវជូនដំណឹងជាមុន ០៥ ថ្ងៃមក ក្រសួងពត៌មានដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

**ប្រការ ២** : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌ អ្នកកាសែតឈរលើស្មារតីទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារ អត្ថបទត្រូវអនុវត្តអោយបានសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជារួចស្មើប្រគល់កាសែតចំនួន០៦ ច្បាប់រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

**ប្រការ ៣** : ក្នុងករណីប្រព្រឹត្តល្មើស អំពីសេចក្តីដូចមានចែងក្នុងប្រការ ១ និងប្រការ ២ ខាងលើនេះ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៤** : អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ–នាយកមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និងលោក ចាងហ្វាងកាសែត « សម្លេងនិស្សិត » ត្រូវអនុវត្តនូវប្រកាសនេះ ។

**ប្រការ ៥** : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ និងចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

**ខៀវ កាញារីទ្ធ**

* * *

**ប្រកាសលេខ ១២៨ ៩៦ ពម.មពប្រក**

**អនុញ្ញាតអោយទស្សនាវដ្ដីឈ្មោះ «ខាំបូឌាដាយរិចតូរី»**

**បោះពុម្ពផ្សាយជាភាសាចិន**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាជំពូក ៣ មាត្រាទី ៤១
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្ដេចព្រះ**នរោត្ដម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្ដីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នសរកម.០៨៩៥.០៧ ចុះថ្ងៃទី ០១ កញ្ញា ១៩៩៥
- បានឃើញសំណើសុំបោះពុម្ពទស្សនាវដ្ដីឈ្មោះ «ខាំបូឌាដាយរិចតូរី» ចុះថ្ងៃទី ២៣ មេសា ១៩៩៦ ។

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយទស្សនាវដ្ដីឈ្មោះ «ខាំបូឌាដាយរិចតូរី» Cambodia Directory បោះពុម្ពផ្សាយ ជាភាសាចិនដោយ មានលោក ចូវ វុណាន់ ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការលេខ ៧១៥ អឺ០ ផ្លូវមុនីវង្ស សង្កាត់បឹងកេងកង ៣ ក្រុងភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្ដូរចំណុចណាមួយ ក្នុងអត្តសញ្ញាណ នៃទស្សនាវដ្ដីរបស់ខ្លួនត្រូវជូនដំណើងជាមុន ០៥ ថ្ងៃមកក្រសួងពត៌មាន ដើម្បីរង់ចាំសេចក្ដីសំរេចជាថ្មី ។

**ប្រការ ២** : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាម គោលការណ៍ក្រមសីលធម៌អ្នកកាសែត និង ឈរលើស្មារតីទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារអត្ថបទត្រូវអនុវត្តន៍អោយបាន សមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជារួចស្នើប្រគល់ទស្សនាវដ្ដីចំនួន ០៦ ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

**ប្រការ ៣** : ក្នុងករណីប្រព្រឹត្តល្មើសអំពីសេចក្ដីដូចមានចែងក្នុងប្រការ ១ និង ប្រការ ២ ខាងលើសាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៤** : អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ – នាយកមណ្ឌលពត៌មាន និង លោកចាង ហ្វាងទស្សនាវដ្ដី «ខាំបូឌាដាយរិចតូរី » Cambodia Directory ត្រូវអនុវត្តនូវប្រកាសនេះ ។

**ប្រការ ៥** : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ និង ចូលជាធរមានចាប់ ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**ខៀវ កាញារីទ្ធ**

* * *

**ប្រកាសលេខ ១២៩ ៩៦ ពម.បលប្រក**

**ស្ដីពីការតែងតាំងមន្ត្រីរាជការក្រសួងពត៌មាន**

រដ្ឋមន្ត្រីក្រសួងពត៌មាន

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាជំពូក ៣ មាត្រាទី ៤១
– បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្ដេចព្រះ**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរដ្ឋាភិបាល
– បានឃើញច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ។
– បានឃើញព្រះរាជក្រមលេខនស.រកម. ០១.៩៦–១៤ ប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងពត៌មាន
– យោងទៅលើការចាំបាច់របស់ក្រសួង
– ពិនិត្យទៅលើលក្ខណៈសម្បត្តិរបស់មន្ត្រីរាជការ

**សំរេច**

**ប្រការ ១** : តែងតាំងលោកស្រី **ឆាន់ មុនី** ជានាយខុទ្ទកាល័យ នៃក្រសួងពត៌មាន

**ប្រការ ២** : លោកនាយកខុទ្ទកាល័យ លោកអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញកិច្ច និង សាមីខ្លួនមាន ភារកិច្ចអនុវត្តតាមសេចក្តីប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**អៀង មូលី**

* * *

**ប្រកាសលេខ ១៣៧ ៩៦ ពម.បសឧ.ប្រក**

**អនុញ្ញាតជូនលោក ថេង ម៉ុនម៉ា បើកអាជីវកម្ម**

**រោងពុម្ពឈ្មោះ « ធី.ប៊ី.អរ »**

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០៧ .១១.៩៣
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២៤.០១.៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន
- យោងលិខិតជូនដំណឹងរបស់ក្រសួងពត៌មានលេខ ១២២៤.៩៤ ពម ចុះថ្ងៃទី ១៤.១១.៩៥ ស្តីពីការបោះពុម្ពផ្សាយ ។
- យោងលិខិតស្នើសុំអនុញ្ញាតច្បាប់បើកអាជីវកម្មរោងពុម្ពឈ្មោះ « ធី ប៊ី អរ » របស់ លោក **ថេង ម៉ុនម៉ា** ចុះថ្ងៃទី ៣០ ខែ មិនា ឆ្នាំ ១៩៩៦ ។

**សំរេច**

**ប្រការ ១** : អនុញ្ញាតជូនលោក **ថេង ម៉ុនម៉ា** ស្ថិតនៅផ្ទះលេខ ៣៧-៣៩ ផ្លូវលេខ ៣១៧ សង្កាត់ វាលវង់ ខ័ណ្ឌ ៧មករា រាជធានីភ្នំពេញបើកអាជីវកម្មរោងពុម្ពដែលមានឈ្មោះ « ធី ប៊ី អរ » ទីតាំងស្ថិតនៅផ្ទះលេខ ២៧២-២៧៤ ផ្លូវលេខ ៩៣ សង្កាត់ទន្លេបាសាក ខ័ណ្ឌដូនពេញ រាជ ធានីភ្នំពេញ ។

**ប្រការ ២** : រាល់ដំណើរការបោះពុម្ពផ្សាយត្រូវអនុវត្តតាមកិច្ចសន្យាសមស្រប ទៅនឹងទំនៀម ទំលាប់សន្តិសុខសណ្តាប់ធ្នាប់សង្គម និង ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៣** : ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ ២ សាមីខ្លួនត្រូវទទួលខុសត្រូវតាម ច្បាប់ជាធរមាន ។

**ប្រការ ៤** : ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ សោតទស្សន៍ នៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ និង ប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តតាមភារកិច្ចរៀងៗ ខ្លួន ។

**ប្រការ ៥** : ប្រកាសនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ. រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**ខៀវ កាញារីទ្ធ**

* * *

## ៤– ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

## ប្រកាស

### ប្រកាសលេខ ២០១ ប្រក. សក.

### ស្តីពីការបង្កើតគណៈកម្មការដឹកនាំបច្ចេកទេសក្នុងគំរោងអភិវឌ្ឍន៍ ផ្លូវជាតិលេខ ១ តំបន់មេគង្គជំនួំពេញ ហូជីមិញ

### (RN 1 HOCHIMINH -Phnom Penh Highway Improvement Project)

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

–យោងកំណត់ហេតុ នៃការចរចាក្នុងកិច្ចសន្យារវាងធនាគារអភិវឌ្ឍន៍អាស៊ី ជាមួយក្រុម ហ៊ុន **Scott Wilson Kirkpatrick United Kingdom in association with BCEOM France** កាលពីថ្ងៃទី ២៥–២៩ មិនា ១៩៩៦

-យោងការងារចាំបាច់របស់ក្រសួង

**សំរេច**

**ប្រការ ១** : បានបង្កើតគណៈកម្មការមួយហៅថា : គណៈកម្មការដឹកនាំបច្ចេកទេស **(Project Steering Committee)** ក្នុងគំរោងអភិវឌ្ឍន៍ផ្លូវជាតិលេខ ១ តំបន់មេគង្គធំ ភ្នំពេញ- ហូជីមិញ **(RN 1 -Phnom Penh-Hochiminh Highway Improvement Project)**

**ប្រការ ២** : គណៈកម្មការនេះមានសមាសភាពដូចខាងក្រោម :

- -ឯកឧត្តម **ឡូវ៉ា អ៊ុំតឹក** រដ្ឋលេខាធិការ ប្រធាន
- -ឯកឧត្តម **មាសកេត្ត កែមរ៉ាន** អនុរដ្ឋលេខាធិការ អនុប្រធាន
- -លោក **តាន់ ហៃសៀន** នាយកនៃនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ សមាជិក
- -លោក **យិន ម៉ុណ្ណា** អនុប្រធានក្លាប់រួមមជ្ឈមណ្ឌលបច្ចេកទេសសាធារណការ (Project Coordinator) សមាជិក
- -លោក **ហែម យឹមអេង** នាយកនាយកដ្ឋានសំណង់អាគារនគរូបនីយកម្ម សមាជិក
- -លោក **អ៊ុំ ជុនហួរ** ប្រធានការិយាល័យត្រួតពិនិត្យយានយន្ត សមាជិក
- -លោក តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- -លោក តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) សមាជិក
- -លោក តំណាងប្រតិភូប្រចាំរាជធានីភ្នំពេញ សមាជិក
- -លោក តំណាងក្រសួងផែនការ សមាជិក
- -លោក តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក
- -លោក តំណាងក្រសួងពាណិជ្ជកម្ម សមាជិក
- -លោក តំណាងក្រសួងការពារជាតិ សមាជិក
- -លោក តំណាងក្រសួងមហាផ្ទៃ សមាជិក
- -លោក តំណាងក្រសួងបរិដ្ឋាន សមាជិក
- -លោក **មាស សាមិត** មន្ត្រីនាំពាក្យក្រសួងសាធារណការ និង ដឹកនាំជញ្ជូន សមាជិក

**ប្រការ ៣** : គណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម :

១–ផ្តល់នូវទិសដៅ គោលនយោបាយសំរាប់ការអនុវត្តន៍គំរោងការ

២–តាមដានទូវការរីកចំរើនទៅមុខ និងផលប្រយោជន៍របស់គំរោងការ

៣–ជួយដោះស្រាយនូវបញ្ហានានា ដើម្បីធានានូវការអនុវត្តន៍គំរោងអោយបានឆាប់រហ័យ និង ប្រកបដោយប្រសិទ្ធភាព ។

៤–ទំនាក់ទំនងសហការអន្តរជាតិរវាងរាជាណាចក្រកម្ពុជាជាមួលសាធារណរដ្ឋសង្គមនិយមវៀតណាម

៥–ផ្តល់យោបល់ជូនរាជរដ្ឋាភិបាលទាំងពីរ ស្តីពីការកែប្រែគំរោងប្លង់

**ប្រការ ៤** : គណៈកម្មការនេះត្រូវធ្វើការប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៥** : បណ្តាស្ថាប័នពាក់ព័ន្ធ ឯកឧត្តមអស់លោកដូចមានឈ្មោះក្នុងគណៈកម្មការនេះត្រូវអនុវត្តន៍សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពល្អចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន
ហត្ថលេខា និង ត្រា
**អ៊ុង គៀត**

* * *

## ៥—ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

## ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ៣៩៧ អយក.ប្រក**

**ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យចក—ជីរលទៅជា**

**«អនុវិទ្យាល័យ ហេង សំរិន » ស្ថិតនៅក្នុងស្រុក អូររាំងឪ ខេត្តកំពង់ចាម**

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យ–ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ
- យោងលិខិតរបស់គណៈកម្មការទ្រទ្រង់អនុវិទ្យាល័យចក–ជីវិល ចុះថ្ងៃទី ០១ កុម្ភៈ ១៩៩៦ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំយុវជន និង កីឡា និង អភិបាលខេត្តកំពង់ចាម
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

**សម្រេច**

**ប្រការ ១** : អនុញ្ញាតប្តូរឈ្មោះអនុវិទ្យាល័យចក–ជីវិល ទៅជា «អនុវិទ្យាល័យ **ហេង សំរិន**» ចាប់ពីឆ្នាំសិក្សា ១៩៩៥–៩៦ តទៅ ។

**ប្រការ ២** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣** : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និងកីឡា –ប្រធានមន្ទីរអប់រំយុវជន និង កីឡាខេត្តកំពង់ចាម និង នាយកអនុវិទ្យាល័យ **ហេង សំរិន** មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

ហត្ថលេខា និង ត្រា

**តុល ឡោះ**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ៣៩៨ អយក. ប្រក**

**ស្តីពីការប្តូរឈ្មោះវិទ្យាល័យខ្សាច់កណ្តាលទៅជា**

**«វិទ្យាល័យ ហ៊ុន សែន » ខ្សាច់កណ្ដាល**

**ស្ថិតនៅក្នុងស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល**

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យ-ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ឆ្នាំ ១៩៨៦ ស្ដីពី ប្រព័ន្ធអប់រំចំណេះទូទៅ
- យោងលិខិតរបស់នាយកអនុវិទ្យាល័យខ្សាច់កណ្ដាល ០១០ វិ.ខ្ស.ក ចុះថ្ងៃទី ០៥ កុម្ភៈ ១៩៩៦ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំយុវជន និង កីឡា និង អភិបាលខេត្តកណ្ដាល
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១** : អនុញ្ញាតប្ដូរឈ្មោះអនុវិទ្យាល័យខ្សាច់កណ្ដាលទៅជា «អនុវិទ្យាល័យ **ហ៊ុន សែន ខ្សាច់កណ្ដាល** » ចាប់ពីឆ្នាំសិក្សា ១៩៩៥-៩៦ តទៅ ។

**ប្រការ ២** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជា និរាករណ៍ ។

**ប្រការ ៣** : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និងកីឡា -ប្រធានមន្ទីរអប់រំយុវជន និង កីឡាខេត្តកណ្ដាល និង នាយកវិទ្យាល័យ **ហ៊ុន សែន ខ្សាច់កណ្ដាល** មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

ហត្ថលេខា និង ត្រា

**តុល ឡោះ**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ៣៩៩.អយក.ប្រក**

**ស្តីពីការពង្រីកអនុវិទ្យាល័យ ទ្រៀល ទៅជា « វិទ្យាល័យទ្រៀល »**

**ក្នុងស្រុកបារាយណ៍ខេត្ត កំពង់ធំ**

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤
- បានឃើញក្រឹត្យ–ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ។
- យោងលិខិតលិខិតសំណើរបស់នាយកអនុវិទ្យាល័យទ្រៀលលេខ ១១៤ អន.ទ.៩៥ ចុះថ្ងៃទី ១៩ ធ្នូ ១៩៩៥ ដោយមានយោបលឯកភាពពីមន្ទីរអប់រំយុវជន និង កីឡា និង អភិបាលខេត្តកំពង់ធំ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយពង្រីកអនុវិទ្យាល័យទ្រៀល ទៅជា «**វិទ្យាល័យ ទ្រៀល** » ចាប់ពីឆ្នាំសិក្សា ១៩៩៦–៩៧ តទៅ នៅក្នុងស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

**ប្រការ ២** : វិទ្យាល័យនេះ ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេង ។ មួយចំនួនទៀត តាមអង្គការលេខ នៃវិទ្យាល័យ ។

**ប្រការ ៣** : នាយក–នាយករង នៃវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់នាយកនាយករង នៃវិទ្យាល័យ ។

**ប្រការ ៣** : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និងកីឡា –ប្រធានមន្ទីរអប់រំយុវជន និង កីឡាខេត្តកំពង់ធំ និង នាយកវិទ្យាល័យ **ខ្មែរវៀល** មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

ហត្ថលេខា និង ត្រា

**តូល ឡោះ**

* * *

**ប្រកាសលេខ ៤០០ អយក.ប្រក**

**ស្តីពីការប្តូរឈ្មោះ «អនុវិទ្យាល័យ កោះចូរ៉ាម »ទៅជា**

**អនុវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន កោះចូរ៉ាម**

**ស្ថិតនៅក្នុងស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល**

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤
- បានឃើញក្រឹត្យ–ច្បាបលេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ។
- យោងលិខិតរបស់គណៈកម្មការទ្រទ្រង់អនុវិទ្យាល័យកោះចូរ៉ាមលេខ ០៤/៩៦ អនុវិ.កចរ ចុះថ្ងៃទី ០១ ខែ កុម្ភៈ ១៩៩៦ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំយុវជន និង កីឡា អភិបាលខេត្តកណ្តាល ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយប្តូរឈ្មោះអនុវិទ្យាល័យកោះចូរ៉ាមទៅជា «**អនុវិទ្យាល័យ ម៉ុនរ៉ានី ហ៊ុន សែន កោះចូរ៉ាម** » ចាប់ពីឆ្នាំសិក្សា ១៩៩៥-៩៦ តទៅ ។

**ប្រការ ២** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣** : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និងកីឡា -ប្រធានមន្ទីរអប់រំយុវជន និង កីឡាខេត្តកណ្តាល និង នាយកអនុ - វិទ្យាល័យ **ម៉ុនរ៉ានី ហ៊ុន សែន កោះចូរ៉ាម** មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

ហត្ថលេខា និង ត្រា

**តុល ឡោះ**

* * *

## ៦-ទីស្តីការក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

## ប្រកាស

ភ្នំពេញ, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ៤៦៤ សករ.**

**ស្តីពីការតែងតាំងទីប្រឹក្សាក្នុងការ**

**បញ្ជូនពលករខ្មែរទៅធ្វើការនៅកោះតៃវ៉ាន់**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១២៩៩៤

– បានឃើញព្រះរាជក្រមលេខ នស.រកម. ០១៩៦.១៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន

– បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាល ស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេស

– តាមសំណើរបស់លោក ស៊ុន លីសេង នាយកក្រុមហ៊ុន ខេមថាយម៉ែនផាវើរ ចុះថ្ងៃ ទី ០៤ ខែ មេសា ឆ្នាំ ១៩៩៦ ។

**សំរេច**

**ប្រការ ១** : តែងតាំងលោក **ឆាត ឆាយឆប់រ៉ាក់ (CHAT CHICHOPRAK)** ហៅ ហួង យ៉េនហុង (HUANG YENHONG) អនុប្រធានក្រុមហ៊ុនខេមថាយម៉ែនផាវើរជាទីប្រឹក្សានៃរដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន ក្នុងការបញ្ជូនពលករខ្មែរអោយប្រើទៅធ្វើការនៅកោះតៃវ៉ាន់ ។

**ប្រការ ២** : លោក **ឆាត ឆាយឆប់រ៉ាក់** ដែលជាទីប្រឹក្សានេះ ត្រូវមានភារកិច្ចដូចតទៅ ÷

១– ទំនាក់ទំនងជាមួយអាជ្ញាធរមានសមត្ថកិច្ចតៃវ៉ាន់ អោយពលករខ្មែរបានចូលទៅបណ្តុះបណ្តាលដើម្បីធ្វើការ ឬទៅធ្វើការនៅទីនោះដោយស្របច្បាប់ ។

២– ទំនាក់ទំនងជាមួយអាជ្ញាធរមានសមត្ថកិច្ចតៃវ៉ាន់ និងបណ្តារោងចក្រសហគ្រាស ដើម្បីបាន quota (ចំនួនកំរិតកំណត់) ពិតប្រាកដក្នុងការបញ្ចូលពលករខ្មែរទៅធ្វើការនៅទីនោះ ។

៣– ក្រោយពេលបានការអនុញ្ញាតជាផ្លូវការពី អាជ្ញារមានសមត្ថកិច្ចតៃវ៉ាន់អោយនាំពលករខ្មែរ ទៅធ្វើការនៅទីនោះហើយ ត្រូវរៀបចំបង្កើតការិយាល័យទំនាក់ទំនងមួយនៅតៃវ៉ាន់ដើម្បីគ្រប់គ្រងពលករទាំងនោះ ។

៤– ទទួលអនុវត្តនូវកិច្ចការផ្សេងៗទៀតជាចាំបាច់ដែលក្រសួងតំរូវអោយធ្វើទាក់ទងទៅនឹងការ បញ្ជូនពលករនេះ ។

**ប្រការ ៣** : លោក **ឆាត ឆាយឆប់រ៉ាក់** ត្រូវអនុវត្តអោយបានល្អនូវភារកិច្ចទាំងបួនដែលបានកំណត់ក្នុងប្រការ ២ ។ ចំពោះភារកិច្ចណាដែលមិនបានចែងច្បាស់ក្នុងប្រការ២ លោក

**ឆាត ឆាយឆប់វ៉ាត់** ត្រូវពិភាក្សាសុំការយល់ព្រមជាមុនពីក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជនសិនទើប អនុវត្តបាន ។

**ប្រការ ៤** : រាល់ការអនុវត្តន៍ខុសពីភារកិច្ចដែលបានកំណត់ខាងលើ ក្រសួងពុំទទួលខុសត្រូវឡើយហើយ ក្នុងករណីចាំបាច់ក្រសួងនឹងសំរេចលុបប្រកាសនេះជាស្ថាពរ លោក **ឆាត ឆាយឆប់វ៉ាត់** ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ។

**ប្រការ ៥** : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**ស៊ុយ សែម**

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៩៥០ រៀល